N° 39
23-10-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣៩ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAM.

Ch. Kimbo

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៩_១០_១៩៩៧ _ព្រះរាជក្រឹត្យ នស/រកត/១០៩៧/៦៧ តែងតាំងលោក
អ៊ឹង ស៊ា ជាឧកញ៉ា ២២៣៣
១៩_១០_១៩៩៧ _ព្រះរាជក្រឹត្យ នស/រកត/១០៩៧/៦៨ តែងតាំងលោក
អ៊ិត ប្រាំង ជាឧកញ៉ា ២២៣៤
១៩_១០_១៩៩៧ _ព្រះរាជក្រឹត្យ នស/រកត/១០៩៧/៦៩ តែងតាំងលោក
ម៉ៅ ភិរុណ ជាឧកញ៉ា ២២៣៥

II . រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៧_១០_១៩៩៧ _អនុក្រឹត្យ លេខ ៦៥ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានស្រាវ
ជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ២២៣៦
២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ៦៦ អនក្រ.បក ស្តីពីការរៀបចំ និងការ
ប្រព្រឹត្តិទៅ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ២២៥១
២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ៦៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ
របស់ក្រសួងសុខាភិបាល ២២៦២

២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ៦៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ២២៧៥
២០_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២៧៧
២១_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៣ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ២២៧៨
២១_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៤ អនក្រ.តត ស្ដីពីការតែងតាំងមុខងារ នាយទាហាន ២២៧៩
២១_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២៨០
២១_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២៨១
២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២៨២
២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២២៨៥
២២_១០_១៩៩៧ _អនុក្រឹត្យ លេខ ២០៩ អនក្រ.តត ស្ដីពីការពន្យារពេលចូល និវត្តន៍មន្ត្រីរាជការ ២២៨៧

២_សេចក្ដីសំរេច

១៦_១០_១៩៩៧ _សេចក្ដីសំរេច លេខ ៣៩ សសរ. ស្ដីពីការបង្កើតគណៈកម្មការ ជាតិ យូណេស្កូកម្ពុជា ២២៨៨
១៦_១០_១៩៩៧ _សេចក្ដីសំរេច លេខ ៤០ សសរ. ស្ដីពីការផ្គត់ផ្គង់ភស្តុភារ សំភារៈ បរិក្ខារ គ្រប់ប្រភេទ និងសំលៀកបំពាក់ឯកសណ្ឋាន សំរាប់កងយោធ ពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងជីវពល និងកងនគរបាល ជាតិ និងសំភារៈបរិក្ខារពេទ្យ សំរាប់មន្ទីរពេទ្យ ជូនក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ២២៩១
១៧_១០_១៩៩៧ _សេចក្ដីសំរេច លេខ ៤១ សសរ. ស្ដីពីការផ្ទេរសិទ្ធិ ២២៩៣

III .ការងារបណ្តាក្រសួង

១-ទីស្តីការគណៈរដ្ឋមន្ត្រី

១_ប្រកាស

២២_១០_១៩៩៧ _ប្រកាស លេខ ១៤៩ ប្រក.បល ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៩៤

២_សេចក្តីសំរេច

២០_១០_១៩៩៧ _សេចក្តីសំរេច លេខ ១៧ សសរ. ស្តីពីការតែងតាំងគណៈមេ
ប្រយោគ សំរាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ
ថ្នាក់មធ្យម ២២៩៦

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

២១_១០_១៩៩៧ _ប្រកាស លេខ ៩៦៤ ផក.ប្រក. អនុញ្ញាតអោយក្រុមហ៊ុន
ហោលឌិន អង្គរស៊ីម៉ងត៍ តំណាងដោយលោក TSUI HOI PAN
សញ្ជាតិចិន ហុងកុង បង្កើតរោងចក្រផលិតស៊ីម៉ងត៍ ២២៩៩

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៧_១០_១៩៩៧ _ប្រកាស លេខ ២៧៨/៩៧ ពម.ប្រក. ស្ដីពីការតែងតាំងមន្ត្រី រាជការ ២៣០០

១៧_១០_១៩៩៧ _ប្រកាស លេខ ២៧៩/៩៧ ពម.ប្រក. ស្ដីពីការតែងតាំងមន្ត្រី រាជការ ២៣០១

១៧_១០_១៩៩៧ _ប្រកាស លេខ ២៨១/៩៧ ពម.ប្រក. ស្ដីពីការតែងតាំងមន្ត្រី រាជការ ២៣០២

២១_១០_១៩៩៧ _ប្រកាស លេខ ២៨៥/៩៧ ពម.ប្រក. អនុញ្ញាតអោយមន្ទីរ ពត៌មាន ខេត្តបាត់ដំបង បើកស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ខេត្តបាត់ដំបង ២៣០៣

២២_១០_១៩៩៧ _ប្រកាស លេខ ២៨៦/៩៧ ពម.ប្រក. ស្ដីពីការតែងតាំងមន្ត្រី រាជការ ២៣០៥

៤_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២១_១០_១៩៩៧ _ប្រកាស លេខ ៧៨៤ អយក. ប្រក. ស្ដីពីការអនុញ្ញាត អោយបើក សាលាបឋមសិក្សាឯកជន អាត់វេនទីសកម្ពុជា ២៣០៦

៥_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

២២_១០_១៩៩៧ _សេចក្ដីសំរេច លេខ ៥៨៣ សសរ.មស.ក្រខ ស្ដីពីការ
បែងចែក និស្សិត ចំនួន ៥០នាក់ ដែលទើបបញ្ចប់ការសិក្សា
ពីបរទេស ២៣០៨

៦_ទីស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

២២_១០_១៩៩៧ _សេចក្ដីសំរេច លេខ ២១១/៩៧ កធស ស្ដីពី
ការរំលាយ «ពុទ្ធិកៈសមាគមន៍អភិវឌ្ឍន៍កម្ពុជា » ២៣១៣

ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត ១០៩៧/៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អ៊ុង ស៊ា

ជា

ឧកញ៉ា

ធ្វើនៅ សៀមរាប ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត ១០៩៧/៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អ៊ិត ប្រាង

ជា

ឧកញ៉ា

ធ្វើនៅ សៀមរាប ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត ១០៩៧/៦៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ម៉ៅ តិរុណា

ជា

ឧកញ៉ា

ធ្វើនៅ សៀមរាប ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៧
ព្រះហស្តលេខា
នរោត្តម សីហនុ

II – រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

អនុក្រឹត្យ លេខ ៦៥ អនក្រ.បក
ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ នស.រកម /០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

– បានឃើញព្រះរាជក្រមលេខ នស.រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត /០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

សម្រេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា១.- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ហៅកាត់ថា (**វសកក**) ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមបទបញ្ញត្តិ នៃអនុក្រឹត្យនេះ ព្រមទាំងបទបញ្ជាផ្ទៃក្នុងមួយ និងបទបញ្ញត្តិពាក់ព័ន្ធដទៃទៀត នាថ្ងៃក្រោយ ។

មាត្រា២.- **វសកក** មាននីតិបុគ្គលភាព និង ស្វ័យភាពហិរញ្ញវត្ថុ ។

មាត្រា៣.-

៣.១. ក្នុងឋានៈជាស្ថាប័នសាធារណៈ **វសកក** ទទួលពីរដ្ឋនូវអំណាច និងពេញកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្ម ស្របតាមកម្មវត្ថុរបស់ខ្លួន ។

៣.២. **វសកក** មានភារកិច្ចដូចតទៅ :

-ដឹកនាំ និង សំរេចរាល់សកម្មភាពស្រាវជ្រាវ និងពិសោធន៍ សំដៅជំរុញការអភិវឌ្ឍន៍លើគ្រប់ផ្នែកនៃដំណាំកៅស៊ូទូទៅ ។

-ចូលរួមក្នុងរាល់សកម្មភាពនៃការជំរុញ ផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និង តម្លៃផលិតកម្ម ។

៣.៣. ដើម្បីអនុវត្តភារកិច្ចខាងលើនេះ **វសកក** មានកាតព្វកិច្ច :

-ទ្រទ្រង់ដល់ការអនុវត្តន៍រាល់កម្មវិធីអភិវឌ្ឍដំណាំកៅស៊ូ តាមការសិក្សាអំពីលក្ខណៈវិនិច្ឆ័យ ការតាមដាន និងវាយតម្លៃលទ្ធផល តាមការរៀបចំសំរួលឯកសារ ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងតាមការធ្វើវិញ្ញាបនកម្មច្បាប់ពូជ ។

-ចាត់ចែងផ្តល់ពូជល្អៗ តាមការបញ្ចូល សាកល្បង បង្កើត បង្កើន និងការផ្សព្វផ្សាយពូជ ។

- ចូលរួមក្នុងការធ្វើអោយមានតម្លៃនូវគុណភាពកៅស៊ូ តាមការគ្រប់គ្រងមន្ទីរពិសោធន៍ជាតិ ផ្នែកយថាប្រភេទ និងតាមការបង្កើតបទដ្ឋានស្តីពីគុណភាព ។
- ចាត់ចែងមធ្យោបាយធ្វើលក្ខណៈវិនិច្ឆ័យ និង វិភាគ ។
- ចូលរួមក្នុងសកម្មភាព ក្នុងការបណ្តុះបណ្តាល ពតិមាន ការផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាថ្មី ។
- និងជាទូទៅ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសំណើរបស់ដៃគូក្នុងប្រទេស និងក្រៅប្រទេស និងចាត់ចែងគ្រប់សកម្មភាពដែលជាអត្ថប្រយោជន៍ ដល់ការអភិវឌ្ឍន៍ប្រព័ន្ធកៅស៊ូ ព្រមទាំងកែលំអនូវការយល់ដឹងក្នុងវិស័យនេះផង ។

ជំពូកទី ២

ការដឹកនាំ និងការគ្រប់គ្រង

ផ្នែកទី ១

អង្គការសំរេចរបស់វិទ្យាស្ថាន

មាត្រា៤.– **វសកក** ត្រូវដឹកនាំដោយក្រុមប្រឹក្សា មួយ ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញបេសកកម្មក្នុងនាម **វសកក** ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

មាត្រា៥.–

៥.១. ក្រុមប្រឹក្សាភិបាល មានសមាជិក ៧រូប ដែលមានសមាសភាពដូចតទៅ :

– តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ប្រធាន
– តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
– ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ	សមាជិកស្វ័យប្រវត្តិ
– នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា	សមាជិកស្វ័យប្រវត្តិ

-តំណាងអ្នកដាំកៅស៊ូ ២ នាក់ សមាជិក

-តំណាងបុគ្គលិកវិទ្យាស្ថាន សមាជិកស្ម័យប្រវត្តិ

៥.២. ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យមួយ សំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងអោយ ។

មាត្រា៦.-

៦.១. ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងធានារបៀបរៀបរយ នៃកិច្ចប្រជុំនេះអោយបានប្រសើរ ។

៦.២. បទបញ្ជាផ្ទៃក្នុងនៃ **ទសកក** អាចអនុញ្ញាតអោយក្រុមប្រឹក្សាភិបាលអញ្ជើញឥស្សរជន នៅក្នុងឬក្រៅវិទ្យាស្ថាននេះ ដែលមានបទពិសោធន៍លើវិស័យកៅស៊ូផ្នែកកសិកម្ម រុក្ខកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ចកៅស៊ូ ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ ឥស្សរជនទាំងនេះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

មាត្រា៧.- ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់វិទ្យាស្ថាន ។

ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ :

-សំរេចផែនការអភិវឌ្ឍន៍នៃ **ទសកក** ស្របតាមទិសដៅកំណត់របស់រដ្ឋាភិបាល ។

-សំរេចលើចំណូល និងចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ទសកក** ។

-ពិនិត្យសំរេចលើរបាយការណ៍គ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

-កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅ ដល់អង្គភាពឯទៀតក្រោមឱវាទ ។

-កំណត់នូវរបបជ្រើសរើស ការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ទសកក** ដោយមិនប៉ះពាល់ដល់បទបញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងាររបស់មុខងារសាធារណៈ ។

-សំរេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតអោយ **ទសកក** ។

-សំរេចលើអនុសញ្ញា កិច្ចសន្យា និងលទ្ធកម្មទាំងឡាយដែលស្របតាម និយាមចែង ក្នុងបទបញ្ជាផ្ទៃក្នុង ឬបទបញ្ញត្តិទាំងឡាយ ដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។

-តាមចន្លោះពេលទៀងទាត់ វាយតម្លៃ គិតលទ្ធផលសំរេចបាននូវគោលដៅ កំណត់ដោយ **ទសភក** ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

មាត្រា៩.-

៩.១.ក្រុមប្រឹក្សាភិបាលនៃ **ទសភក** ត្រូវធ្វើការប្រជុំនៅពេលណា ដែលផលប្រយោជន៍របស់ **ទសភក** តម្រូវនិងត្រូវធ្វើការយ៉ាងតិចមួយឆមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក៣នាក់ ឬតាមការស្នើសុំពីនាយកនៃ **ទសភក** ។ របៀបវារៈ ព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច១០ថ្ងៃ មុនថ្ងៃប្រជុំ ។

៩.២.ការប្រជុំនៃក្រុមប្រឹក្សាភិបាល អាចទទួលយកជាការបាន លុះត្រាតែសមាជិកវត្តមាន មានចំនួន ៤នាក់យ៉ាងតិច នៃបណ្តាសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងអោយមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើសម្លេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ៨ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយសេចក្តីសំរេចប្រជុំលើកក្រោយនេះ មិនទាមទារសម្លេងកូរ៉ុមទេ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើន នៃសមាជិកវត្តមាន ។ ក្នុងករណីមានការចែកសំលេងនោះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវមានឧត្តមានុភាព ។

៩.៣.សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងបញ្ជីពិសេសមួយ តំកល់ទុកនៅទីស្នាក់ការរបស់វិទ្យាស្ថាន និងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងនាយក **ទសភក** ដែលមានតួនាទីជាលេខានៃសម័យប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យ នៃការពិភាក្សាអោយបានច្បាស់លាស់ និងត្រូវផ្ញើជូនគ្រប់សមាជិកនិងក្រសួងពាក់ព័ន្ធទាំងឡាយយ៉ាងយូរ ១០ថ្ងៃក្រោយពេលប្រជុំ ។

ផ្នែកទី ២

អង្គការប្រតិបត្តិរបស់វិទ្យាស្ថាន

មាត្រា១០.– **វសកករ** ត្រូវគ្រប់គ្រងដោយនាយកមួយរូប ដែលតែងតាំងដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ នាយកអាចត្រូវបានបញ្ឈប់គ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា១១.–

១១.១. នាយក **វសកករ** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រង **វសកករ** លើកលែងតែសិទ្ធិដែលមានចែងក្នុងច្បាប់ និងបទបញ្ជាផ្ទៃក្នុង ដែលជាសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល ។

នាយក :

- រៀបចំ និងចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។
- ទទួលបន្ទុកអនុវត្តសេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់អោយដំណើរការនូវនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សានេះ ។
- រៀបចំថវិកាប្រចាំឆ្នាំសំរាប់ **វសកករ** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។
- ធ្វើរបាយការណ៍ប្រចាំឆ្នាំលើរាល់សកម្មភាព ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ ។
- បំពេញរាល់មុខតំណែងរបស់ **វសកករ** ក្នុងក៏រិតក្របខ័ណ្ឌចំនួនបុគ្គលិក កំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- បំពេញតួនាទីជាឋានានុក្រមថ្នាក់លើ ចំពោះបុគ្គលិកទាំងមូលនៃ **វសកករ** ។
- ចុះកិច្ចសន្យា និងចុះហត្ថលេខា លើអនុសញ្ញាទាំងឡាយ ដែលស្របតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទបញ្ញត្តិដទៃទៀត ស្តីពីបញ្ហានេះ ។

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយ ដែលត្រូវបានប្រគល់ជូន ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ទសភក** និងដោយសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

១១.២. នាយក **ទសភក** ជាតំណាងវិទ្យាស្ថាន ចំពោះមុខតតិយជនទាំងឡាយ ។

១១.៣. នាយក **ទសភក** ត្រូវអនុវត្តគោលនយោបាយ និងសេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងរាយការណ៍ អំពីការអនុវត្តន៍ ។

១១.៤. នាយក **ទសភក** ត្រូវស្នើទៅក្រុមប្រឹក្សាភិបាលសុំតែងតាំងនាយករងមួយរូប ឬច្រើនរូប ដើម្បីជួយការងាររបស់ខ្លួន ។

ផ្នែកទី ៣

បុគ្គលិករបស់ « ទសភក »

មាត្រា១២.-

១២.១. បុគ្គលិកអចិន្ត្រៃយ៍របស់ **ទសភក** រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬពីក្រសួងមានសមត្ថកិច្ចផ្សេងៗផ្លាស់បញ្ចូលមក ឬដាក់នៅក្រៅតំណែង អម **ទសភក** តាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងលិខិតបទដ្ឋាននានា ស្ដីពីវិស័យមុខងារសាធារណៈ ឬជ្រើសរើសតាមសំណើ ឬដោយមានការយល់ព្រមពីនាយក **ទសភក** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុក នូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កំរៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

១២.២. វិទ្យាស្ថានអាចជ្រើសរើស ភ្នាក់ងារជាប់កិច្ចសន្យាជំនួយការ និងបុគ្គលិកអណ្ដែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទបញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងសេចក្ដីទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ។

១២.៣. បុគ្គលិក **ទសភក** ត្រូវគ្រប់គ្រងដោយបទបញ្ជាផ្ទៃក្នុង ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។ បទបញ្ជាផ្ទៃក្នុង និងក្រុមប្រឹក្សាភិបាល កំណត់អំពីប្រាក់កំរៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផង ។

ផ្នែកទី ៤

ទ្រព្យសម្បត្តិរបស់ « ខសកក »

មាត្រា១៣ .–

១៣.១. **ខសកក** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

–មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ដំណាំកៅស៊ូ មានផ្ទៃដី ៨៩៣.៥៥ ហិកតា ស្ថិតនៅឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានផែនទីបញ្ជាក់ទីតាំងភ្ជាប់ជាឧបសម្ព័ន្ធក្នុងអនុក្រឹត្យនេះ ។

–អគារមួយដែលប្រើប្រាស់ជាមន្ទីរពិសោធន៍ជាតិ ពិនិត្យ និងវាយតម្លៃគុណភាពជ័រកៅស៊ូ ស្ថិតនៅលើដីឡូត៍លេខ៩ ផ្លូវតឹមអ៊ីលស៊ុង សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

–អគារមួយដែលបំរុងធ្វើជាទីស្នាក់ការកណ្តាលនៃ **ខសកក** ស្ថិតនៅលើដីឡូត៍លេខ ៧៥ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

១៣.២. ក្រៅពីអចលនទ្រព្យខាងលើ **ខសកក** ត្រូវបានទទួលនូវចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៣.៣. អចលនទ្រព្យ និងចលនទ្រព្យទាំងអស់របស់ **ខសកក** នឹងមានចែងលំអិតក្នុងបញ្ជីសារពើភ័ណ្ឌ ។

១៣.៤. វិទ្យាស្ថានអាចទិញ-លក់ ចលនទ្រព្យ និង អចលនទ្រព្យ ចាំបាច់សំរាប់ដំណើរការរបស់ខ្លួន ។

ផ្នែកទី ៥

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ « ខសកក »

មាត្រា១៤.– ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ **ខសកក** ត្រូវប្រព្រឹត្តិស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ៨២ ចុះថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

មាត្រា១៥ .– នាយក **ខសកក** ជាអាណាប័កចំបងក្នុងការចំណាយថវិកានៃវិទ្យាស្ថាន ។

១៥.១.ក្នុងន័យនេះ និងអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន នាយក **ទសភក** ត្រូវ :

–ពិនិត្យកត់ត្រា និងទូទាត់ប្រាក់ចំណូល

–ជំរះ និងបញ្ជាចំណាយ

១៥.២.នាយកអាចផ្តល់សិទ្ធិទៅអាណាប័កប្រតិភូ ១រូប ។ អាណាប័កចំបុងអាច បង្កើតផ្នែកគ្រប់គ្រងចំណូល ឬប្រចាក់បុរេប្រទាន ដោយមានការយល់ព្រមពីភ្នាក់ងារ គណនេយ្យ របស់វិទ្យាស្ថានផង ។

មាត្រា១៦ .–

១៦.១.ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវប្រព្រឹត្តតាមបទបញ្ញា ផ្ទៃក្នុងរបស់វិទ្យាស្ថាន ក្រោមការទទួលខុសត្រូវជាបុគ្គល និងជាប្រាក់កាស របស់ ភ្នាក់ងារគណនេយ្យ ក្នុងឋានៈជាគណនេយ្យករសាធារណៈ ។ ភ្នាក់ងារនេះត្រូវ តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួង កិច្ច និងហិរញ្ញវត្ថុ ហើយធ្វើសម្បថ មុនទទួលតំណែងខ្លួន ។ ភ្នាក់ងារគណនេយ្យនេះ មានសិទ្ធិចូលរួមប្រជុំជាមួយ ក្រុមប្រឹក្សាភិបាលផ្តល់មតិ តែឥតមានសំឡេងឆ្នោតឡើយ ។

១៦.២. ភ្នាក់ងារគណនេយ្យត្រូវទទួលបន្ទុក :

–ប្រមូលប្រាក់ចំណូល

–ទូទាត់ប្រាក់ចំណាយ

–ថែរក្សា និងគ្រប់គ្រងមូលនិធិ និងធនធានវិទ្យាស្ថាន

–ថែរក្សាសក្ខីប័ត្រ និងកាន់កាប់គណនេយ្យ ។

១៦.៣. ភ្នាក់ងារគណនេយ្យ អាចប្រគល់សិទ្ធិទៅអោយអាជ្ញានុការីរបស់ខ្លួន ។

មាត្រា១៧ .–

១៧.១.ធនធានរបស់ **ទសភក** បានមកពី :

–ប្រាក់ឧបត្ថម្ភដំបូងរបស់រដ្ឋ នៅពេលបង្កើតវិទ្យាស្ថាន ។

-ឧបត្ថម្ភធននៃដំណើរការ និងឧបត្ថម្ភជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ។

-ប្រាក់ឧបត្ថម្ភដែលបានមកពី អំណោយ និងអច្ច័យទាន ។

-ប្រាក់ខ្ចីបុលដោយវិទ្យាស្ថានផ្ទាល់ ឬប្រាក់ដែលរដ្ឋអោយខ្ចីបុល ។

-ចំណូលពីការងារ និងការផ្តល់សេវាកម្មនៃ **ទសករក** ។

-ប្រាក់កាតព្វកិច្ចពីគ្រប់អតិថិជន និងអ្នកវិនិយោគដំណាំកៅស៊ូទាំងរដ្ឋ និងឯកជន លើទឹកដីកម្ពុជា ។

-ប្រាក់កំរៃដែលបានមកពីការលក់ ឬការជួលចលនវត្ថុ ឬអចលនវត្ថុ របស់ **ទសករក** ។

១៧.២. ចំណូល និងចំណាយជាប្រក្រតី ឬចំណូលនិងចំណាយជាដើមទុនរបស់ **ទសករក** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន ។ បទបញ្ជាផ្ទៃក្នុង នៃវិទ្យាស្ថាន ត្រូវបញ្ជាក់អំពីបែបបទនៃការរៀបចំនិងការអនុវត្តន៍ថវិកា ។

១៧.៣. ថវិកាត្រូវរៀបចំដោយអាណាប័កចំបងនៃ **ទសករក** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។ ថវិកាត្រូវមានលំនឹង រវាងចំណូលនិងចំណាយ ។ ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តគំរោងថវិកានេះអោយបានមុនថ្ងៃ៣០ ខែ កញ្ញា រៀងរាល់ឆ្នាំ ។

មាត្រា១៨ .-

១៨.១. គណនេយ្យរបស់ **ទសករក** រួមមាន :

-គណនេយ្យទូទៅ តាមបែបបទទ្វេភាគ សំរាប់កត់ត្រាប្រតិបត្តិការផ្នែកថវិកា ផ្នែករតនាគារ និងជាមួយតតិយជន ។

–គណនេយ្យ អចលនវត្ថុ រូបធាតុ និងទ្រព្យ ។

–គណនេយ្យវិភាគ (ប្រសិនបើចាំបាច់) ។

គណនេយ្យវិទ្យាស្ថាន ត្រូវអនុលោមតាមវិធាននៃប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគោរពនូវគំរោងគណនេយ្យរបស់ **ទសកក** កំណត់ដោយក្រុមប្រឹក្សាភិបាល ហើយដែលបានទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.២. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់វិទ្យាស្ថាន ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យតាមរយៈនាយក ដោយមានភ្ជាប់នូវរបាយការណ៍ ស្ដីពីការគ្រប់គ្រងរបស់ខ្លួន ។ ក្រុមប្រឹក្សាភិបាលធ្វើការអនុម័តក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយពេលបិទការិយបរិច្ឆេទគណនេយ្យទាំងឡាយនេះ ។

មាត្រា១៩ .–មូលនិធិ នៃ **ទសកក** ត្រូវតំកល់ក្នុងគណនីចរន្តនៅធនាគារប្រតិស្រុតណាមួយ ។

ផ្នែកទី ៦

របបសារពើពន្ធ និង ពន្ធគយ

មាត្រា២០.– លើកលែងបទបញ្ញត្តិផ្ទុយពីនេះ **ទសកក** ត្រូវស្ថិតនៅក្រោមរបបពន្ធគយ និងពន្ធអាករទាំងឡាយ ស្របតាមច្បាប់ជាធរមាន ដូចគ្នានឹងអង្គភាពរដ្ឋបាលផ្សេងៗទៀតដែរ ។

ផ្នែកទី ៧

លទ្ធកម្ម របស់ « ទសកក »

មាត្រា២១.–ការសំរេច ការអនុវត្តន៍ និងការត្រួតពិនិត្យលទ្ធកម្មរបស់ **ទសកក** ត្រូវគ្រប់គ្រងតាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៦០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្ដីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ និងច្បាប់ផ្សេងទៀត ស្ដីពីចំណុចនេះ ។

ជំពូកទី៣

អាណាព្យាបាលលើ « ទសកក »

មាត្រា២២.— **ទសកក** ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា២៣.—

២៣.១. **ទសកក** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុនូវឯកសារ ដូចតទៅ:

- –កំណត់ហេតុ កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល
- –គំរោងអភិវឌ្ឍន៍របស់វិទ្យាស្ថាន
- –ថវិកាប្រចាំឆ្នាំ
- –របាយការណ៍ គ្រប់គ្រង និងគណនី ហិរញ្ញវត្ថុប្រចាំឆ្នាំ

២៣.២. ឯកសារទាំងនេះ ត្រូវផ្ញើជូនតម្បជនដូចខាងលើនេះយ៉ាងយូរ ១៥ថ្ងៃ ក្រោយថ្ងៃបិទកាលបរិច្ឆេទ នៃឯកសារទាំងនេះ ។

ផ្នែក ទី ១

អាណាព្យាបាលបច្ចេកទេស

មាត្រា២៤.—

២៤.១. គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំនៃ **ទសកក** ត្រូវផ្ញើជូនរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយនាយក **ទសកក** ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយការអនុម័ត នៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់មតិទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវផ្តល់ការយល់ព្រមក្នុងរយៈពេល ២ខែ ចាប់ពីថ្ងៃទទួលឯកសារទាំងនេះ ។

២៤.២. លិខិតផ្តល់ការយល់ព្រម ចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឬតំណាងត្រូវផ្ញើជូនទៅនាយក **ទសភក** និងត្រូវចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយក **ទសភក** ត្រូវបញ្ជូនពត៌មាននេះអោយក្រុមប្រឹក្សាភិបាលបានជ្រាបយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើ គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានយោបល់ជំទាស់ ក្រុមប្រឹក្សាភិបាលត្រូវប្រជុំគ្នាអោយបានឆាប់រហ័សបំផុត ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

គំរោងអភិវឌ្ឍន៍ នៃ **ទសភក** មិនអាចអនុវត្តបាន បើសិននៅមានការមិនចុះសំរុងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ថវិកាចំណាយប្រក្រតីត្រូវអនុវត្តផ្អែកលើ «ប្រព័ន្ធបែងចែកជា ១២ខែ » បើសិនជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែមានមតិមិនចុះសំរុងតទៅទៀត ។

មាត្រា២៥.–

២៥.១. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចមានយោបល់ជំទាស់លើឯកសារដែលបានទទួល ដូចមានចែងក្នុងមាត្រា ២៣ខាងលើនេះ ហើយមានរយៈពេល ១ខែ ដើម្បីលើកមតិជំទាស់លើឯកសារទាំងនេះ ។

២៥.២. នាយក **ទសភក** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងសម័យប្រជុំយ៉ាងឆាប់មួយ ។ ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សារកមធ្យោបាយ ដើម្បីដោះស្រាយអោយបានឆាប់រហ័ស ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសំរេចពុំយកជាការ នូវខ្លឹមសារនៃការជំទាស់ទាំងនោះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើសេចក្តីពន្យល់ជាលាយលក្ខអក្សរ ជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

មាត្រា២៦.–

២៦.១. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបដិសេធ ឬផ្អាករាល់សេចក្តីសំរេចរបស់វិទ្យាស្ថាន ដែលមិនស្របតាមភារកិច្ចរបស់វិទ្យាស្ថាន ហើយដែលផ្ទុយនឹងច្បាប់ ឬបទបញ្ញាផ្សេងៗ ។

២៦.២. ការបដិសេធ ឬការផ្អាក ត្រូវបានសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការផ្តើមគំនិតរបស់ខ្លួន ឬតាមការស្នើសុំពីភាគីពាក់ព័ន្ធ ។ ការបដិសេធឬការផ្អាកនេះ ត្រូវបានជូនដំណឹងជាលាយល័ក្ខអក្សរទៅនាយក **វសកកក** ដែលនឹងត្រូវជូនដំណឹងជាបន្ទាន់ ទៅក្រុមប្រឹក្សាភិបាល ។

មាត្រា២៧.– រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសុំអោយមានការត្រួតពិនិត្យ **វសកកក** តាមតំរូវការនិងស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធនឹងកិច្ចការត្រួតពិនិត្យនេះ ។

ផ្នែកទី២

អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា២៨.–

២៨.១. គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំ ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយនាយក **វសកកក** ក្នុងរយៈពេល១៥ថ្ងៃ ក្រោយការអនុម័តនៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវផ្តល់មតិទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់ការយល់ព្រមក្នុងរយៈពេល ២ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។

២៨.២. លិខិតផ្តល់ការឯកភាព ត្រូវចុះហត្ថលេខាដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាងត្រូវផ្ញើទៅនាយក **វសកកក** ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ នាយក **វសកកក** ត្រូវជូនញត្តិមាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាមានការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល អោយបានឆាប់រហ័ស ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំទាំងឡាយ ត្រូវចាត់ទុកថាគ្មានការយល់ព្រម បើសិនជាការមិនចុះសំរុងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនទាន់ត្រូវដោះស្រាយបាន ។

មាត្រា២៩.– លិខិតដូចខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ទសករ** ត្រូវដាក់សុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្លងតាមយោបល់របស់រដ្ឋមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ :

- ការលក់អចលនទ្រព្យ
- ការលុបចោលនូវគណនេយ្យ ដែលមានទឹកប្រាក់លើសកំរិតទឹកប្រាក់មួយមានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ការសំរេចខ្ចីបុល ឬកិច្ចព្រមព្រៀងធានា ឬលិខិតស្នាម ដែលមានកម្មវត្ថុប្រហាក់ប្រហែលគ្នានេះ ។

មាត្រា៣០.– រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ទសករ** ។ មន្ត្រីនេះមានភារកិច្ចត្រួតពិនិត្យ មុនទង្វើនិងក្រោយទង្វើ ស្របតាមអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្រសួង ខេត្ត -ក្រុង និង អង្គការសាធារណរដ្ឋបាលទូទៅ ។

មាត្រា៣១.–

៣១.១. ការគ្រប់គ្រងដោយអាណាប័កចំបងនៃ **ទសករ** ស្ថិតនៅក្រោមការត្រួតពិនិត្យ នៃអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣១.២. ការគ្រប់គ្រងរបស់ភ្នាក់ងាររគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យនៃគណនេយ្យ កណ្តាលរបស់រតនាគារជាតិ និងក្រោមការត្រួតពិនិត្យនៃអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣១.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់តាំងអោយមានការត្រួតពិនិត្យរួមអធិការកិច្ច ឬពិនិត្យលើផ្នែកណាមួយ ដែលយល់ថាចាំបាច់ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ នឹងកិច្ចត្រួតពិនិត្យនេះ ។

ជំពូកទី ៤

អវសានបញ្ញត្តិ

មាត្រា៣២.–

៣២.១. បទបញ្ញត្តិទាំងឡាយ ដែលមានពីមុន ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

៣២.២. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ ។

៣២.៣. អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ៦៦ អនក្រ.បក

ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

រាជរដ្ឋាភិបាល

–បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែ សីហា ឆ្នាំ ១៩៩៧

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា១.- អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងបណ្តានាយកដ្ឋាននានា ។

ជំពូក២

បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា២.– ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣.– ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានមុខងារ និងភារកិច្ចដូចតទៅ :

១–ប្រតិបត្តិសេវាកម្មអាជីវកម្មផ្នែកការងារមូលដ្ឋានខាងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍

២–ធ្វើជាដៃគូរនៃសម្ព័ន្ធអាជីវកម្មផ្នែកទូរគមនាគមន៍និងការងារប្រៃសណីយ៍

៣–ផ្តល់អាជ្ញាប័ណ្ណ កសាងបញ្ញត្តិអធិការកិច្ច កសាងស្តង់ដា និងគ្រប់គ្រងរលកអាកាសវិទ្យុគ្រប់ប្រភេទ

៤–កសាងគោលនយោបាយ និង ផែនការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងប្រៃសណីយ៍

៥–គ្រប់គ្រង ដឹកនាំការងារប្រៃសណីយ៍ និងការងារទូរគមនាគមន៍ទូទាំងប្រទេស

៦–ហត្ថលេខីជាមួយអន្តរជាតិខាងប្រៃសណីយ៍ និងទូរគមនាគមន៍ និងជាតំណាងរាជរដ្ឋាភិបាលក្នុងអង្គការចាត់តាំងអន្តរជាតិខាងប្រៃសណីយ៍ និង ទូរគមនាគមន៍

៧–បណ្តុះបណ្តាលអ្នកបច្ចេកទេសជំនាញគ្រប់ផ្នែកប្រៃសណីយ៍ និង ទូរគមនាគមន៍

មាត្រា៤.– ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានរចនាសម្ព័ន្ធដូចតទៅ :-

–ខុទ្ទកាល័យ

–នាយកដ្ឋានរដ្ឋបាលបណ្តុះបណ្តាល និង ហិរញ្ញវត្ថុ

- អធិការដ្ឋាន
- អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍
- គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល
  - ទូរគមនាគមន៍កម្ពុជា
  - ប្រៃសណីយ៍កម្ពុជា

អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យ

មាត្រា៥.– ខុទ្ទកាល័យនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យ លេខ២០ អនក្រ–បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក៤

អធិការដ្ឋាន

មាត្រា៦.– អធិការដ្ឋានរបស់ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- ធ្វើរបាយការណ៍ជូនរដ្ឋលេខាធិការ ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការបានប្រគល់ទុកចិត្តអធិការដ្ឋានដឹកនាំដោយអធិការមួយនាក់ អាចអមដោយអធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

ជំពូក ៥

នាយកដ្ឋានរដ្ឋបាល បណ្ដុះបណ្ដាល និង ហិរញ្ញវត្ថុ

មាត្រា៧.- នាយកដ្ឋានរដ្ឋបាល បណ្ដុះបណ្ដាល និងហិរញ្ញវត្ថុ ទទួលបន្ទុក :

ក-ក្នុងវិស័យរដ្ឋបាល :

-សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្ដាល និងរវាងថ្នាក់កណ្ដាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ

-គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង

-សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង.

ខ-ក្នុងវិស័យគ្រប់គ្រងបុគ្គលិក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការនិងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតម្លៃតម្រូវការក្នុងការបណ្ដុះបណ្ដាលបុគ្គលិក

-រៀបចំនយោបាយបណ្ដុះបណ្ដាលដំបូង និងបន្ត ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តន៍នយោបាយនោះ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

គ-មជ្ឈមណ្ឌលបណ្ដុះបណ្ដាលបច្ចេកទេសប្រៃសណីយ៍និងទូរគមនាគមន៍ :

-រៀបចំកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈអ្នកបច្ចេកទេសប្រៃសណីយ៍និងទូរគមនាគមន៍

-បណ្ដុះបណ្ដាលកម្មករ អ្នកបច្ចេកទេស អ្នកនាំសារ លេខាធិការ អ្នកត្រួតពិនិត្យ និងរៀបចំបង្រៀនវិក្រឹតការដល់បុគ្គលិក

-រៀបចំបង្រៀនពតិមានវិទ្យា និងបង្រៀនភាសាបរទេស

ឃ-ក្នុងវិស័យគ្រប់គ្រងសំភារៈ និង បរិក្ខារ :

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំផ្គត់ផ្គង់សំភារៈ និងបរិក្ខាររបស់ក្រសួង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់

-ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត-ក្រុងនានា

-កាន់បញ្ជីជាប្រចាំនូវសលាកបត្រ និងគណនេយ្យរូបធាតុ

-ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី

-ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ

ង-ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ :

-លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ

-ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា

-តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស

-ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ

ជំពូក ៦

អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍

មាត្រា៨.- អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួលគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ នយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ និងនយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ ដឹកនាំដោយអគ្គនាយកមួយរូប ដែលអាចអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ មាននាយកដ្ឋានចំណុះចំនួន៤ :

-នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ
-នាយកដ្ឋាននយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ
-នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
-នាយកដ្ឋាននយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ

មាត្រា៩.- នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ ទទួលបន្ទុកតាក់តែងវិធាននៃការប្រព្រឹត្តិទៅនៃរលកអាកាសវិទ្យុ ជាពិសេស នាយកដ្ឋានត្រូវ :

-រៀបចំតម្លើងស្តង់ដាវិទ្យុគមនាគមន៍
-តាក់តែងឯកសារគំរូសំរាប់ផ្តល់ការយល់ព្រមដល់ការប្រើប្រាស់ស្តង់ដា
-តាក់តែងការអនុវត្តន៍ពតិមានវិទ្យា
-សំរបសំរួលក្នុងការប្រើប្រាស់រយៈពេលវែង ស៊ីចរលកវិទ្យុ និងក្នុងការបញ្ចូលស៊ីចរលកវិទ្យុក្នុងទំនាក់ទំនងអន្តរជាតិ
-ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់រលកវិទ្យុ
-បែងចែកអាជ្ញាប័ណ្ណជូនបណ្តាការីដែលស្នើសុំ
-ដោះស្រាយវិវាទ និងវិបត្តិដែលមានជាមួយបណ្តាការី
-ផ្តល់ការយល់ព្រមលើបរិក្ខាររបស់បណ្តាការីដែលត្រូវតភ្ជាប់ទៅនឹងបណ្តាញទូរស័ព្ទ

មាត្រា១០.- នាយកដ្ឋាននយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកតាក់តែងនយោបាយរយៈពេលវែង កំណត់បញ្ជីតម្លៃផ្សេងៗ រៀបចំនិងការតាមដានទំនាក់ទំនងអន្តរជាតិក្នុងវិស័យនេះ ។ ជាពិសេស នាយកដ្ឋានត្រូវ :

-កំណត់នយោបាយរបស់កម្ពុជា អំពីទូរគមនាគមន៍រយៈពេលវែង និងតាក់តែងច្បាប់ ស្តីអំពីទូរគមនាគមន៍ ។
-តាមដានពីការបោះទីតាំងអង្គភាពទូរស័ព្ទមូលដ្ឋានរបស់គ្រឹះស្ថានសាធារណៈទូរគមនាគមន៍ កម្ពុជានិងរបស់បណ្តាការីនៅតាមខេត្ត និងស្រុកនីមួយៗ
-រៀបចំរបាយការណ៍ប្រចាំខែរបស់ក្រសួង ស្តីពីការរីកចំរើនរបស់អង្គភាពមូលដ្ឋានទាំងនោះ

- តាក់តែងបញ្ជីតម្លៃផ្សេងៗ ដោយយកចិត្តទុកដាក់ពីទិដ្ឋភាពសង្គម និងតំបន់
- ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការប្រជុំជាអន្តរជាតិ ស្តីពីបញ្ជីតម្លៃជាទ្វេភាគី ពហុភាគីមានជាអាទិ៍ សហភាពទូរគមនាគមន៍អន្តរជាតិ
- ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅក្នុងការប្រជុំអន្តរជាតិនានា ។
- សំរបសំរួលកិច្ចព្រមព្រៀងទ្វេភាគីក្នុងវិស័យទូរគមនាគមន៍

មាត្រា១១.– នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលបន្ទុកតាក់តែងវិធានការណ៍នៃការប្រព្រឹត្តិទៅក្នុងការបញ្ជូនបញ្ញើផ្សេងៗ លិខិត និងឯកសារ ។ ជាពិសេស នាយកដ្ឋានត្រូវ :

- កំណត់ពីតម្រូវការនៃសេវាសាធារណៈ
- កំណត់ពីបទបញ្ញាក្នុងការប្រជែងគ្នា
- ផ្តល់ការយល់ព្រមលើបញ្ជីតម្លៃប្រៃសណីយ៍

មាត្រា១២.– នាយកដ្ឋាននយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកតាក់តែងនយោបាយ រយៈពេលវែង និងតាមដានទំនាក់ទំនងអន្តរជាតិក្នុងវិស័យប្រៃសណីយ៍ ។ ជាពិសេសនាយកដ្ឋានត្រូវ :

- កំណត់នយោបាយរបស់កម្ពុជា អំពីប្រៃសណីយ៍រយៈពេលវែង និងតាក់តែងច្បាប់ស្តីពីប្រៃសណីយ៍
- ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការប្រជុំអន្តរជាតិនានា
- សំរបសំរួលកិច្ចព្រមព្រៀងទ្វេភាគីក្នុងវិស័យប្រៃសណីយ៍

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា១៣.– នៅតាមបណ្តាខេត្ត–ក្រុងនីមួយៗ មានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ខេត្ត–ក្រុង មួយដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៨

គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល

មាត្រា១៤._ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវមានគ្រឹះស្ថានសាធារណៈពីរដែលមានឧបនិស្ស័យសេដ្ឋកិច្ច ក្រោមអាណាព្យាបាល ដូចតទៅ :

_គ្រឹះស្ថានសាធារណៈទូរគមនាគមន៍កម្ពុជា

_គ្រឹះស្ថានសាធារណៈប្រៃសណីយ៍កម្ពុជា

មាត្រា១៥._ ការរៀបចំនិងការប្រព្រឹត្តិទៅរបស់គ្រឹះស្ថានសាធារណៈខាងលើនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ដែលបញ្ជាក់ពីលក្ខន្តិកៈដោយឡែករបស់ខ្លួន ដោយអនុលោមតាមព្រះរាជក្រម ជស/រកម/០៦៩៦ ចុះថ្ងៃទី១៧-៦-១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

ជំពូក ៩

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៦._ អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

ជំពូក ១០

អវសានប្បញ្ញត្តិ

មាត្រា១៧: ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

មាត្រា១៨._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៩.-សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា២០ .-អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍



អនុក្រឹត្យលេខ ៦៧ អនក្រ.បក
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

* * *

រាជរដ្ឋាភិបាលកម្ពុជា

Min. Health

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/ /៩០ ចុះថ្ងៃទី៣១ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ១៩៩៧

ជំពូក ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.– អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងសុខាភិបាល និងកំណត់ បេសកកម្ម របស់ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និងបណ្តានាយកដ្ឋាននានា ។

ជំពូក២

បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា២.–ក្រសួងសុខាភិបាលត្រូវ បានរាជរដ្ឋាភិបាល ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យសុខាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣.–ក្រសួងសុខាភិបាល មានមុខងារ និងភារកិច្ច ដូចតទៅ ៖

–កំណត់នយោបាយសុខាភិបាល ដោយផ្អែកលើមូលដ្ឋានកម្មវិធីរបស់រាជរដ្ឋាភិបាល សំដៅលើកកំពស់សុខភាព និង សុខមាលភាពរបស់ប្រជារាស្ត្រ ។

–ធ្វើផែនការ និងរៀបចំយុទ្ធសាស្ត្រសំរាប់វិស័យសុខាភិបាល

–រៀបចំលិខិតបទដ្ឋានសំដៅធានាជាអតិបរិមាគុណភាពសុខាភិបាលសាធារណៈ និងឯកជន ។

–តាមដានរំលឹកត្រួតពិនិត្យ និង វាយតម្លៃការងាររដ្ឋបាល និង បច្ចេកទេសនៃអង្គភាពសុខាភិបាល ស្របតាមច្បាប់និងលិខិតបទដ្ឋានដែលបានដាក់ចេញអោយអនុវត្តជាផ្លូវការ ។

–សិក្សារកមធ្យោបាយនានា សំរាប់អភិវឌ្ឍន៍ផ្នែកសុខាភិបាល និងគ្រប់គ្រងបណ្តាធនធានមនុស្ស សំភារៈ ហិរញ្ញវត្ថុ និងពត៌មាន អោយសមស្របទៅនឹងប្រព័ន្ធសុខាភិបាលសាធារណៈ នៅថ្នាក់កណ្តាល ខេត្ត–ក្រុង រាជធានី ស្រុក ខ័ណ្ឌ –ឃុំ និង សង្កាត់ ។

–រៀបចំកម្មវិធីបង្ការ និងថែទាំវេជ្ជសាស្ត្រ សំដៅបំបាត់ ឬកាត់បន្ថយស្ថានិករោគ ដែលមាននៅក្នុងប្រទេស ។

-សំរបសំរួលធនធាននានា អោយស្របទៅតាមតំរូវការនិងអោយទទួលបានទិន្នផលល្អប្រសើរ ។

-គ្រប់គ្រងប្រព័ន្ធផលិតកម្ម អាជីវកម្ម និងបែងចែកឱសថ បរិក្ខារអមវេជ្ជសាស្ត្រ និងសំភារៈវេជ្ជសាស្ត្រជូនដល់គ្រប់អង្គភាពសាធារណៈ និង ឯកជន ។

-ពិនិត្យតាមដានសុវត្ថិភាពចំណីអាហារ ។

មាត្រា៤.- ក្រសួងសុខាភិបាលមានរចនាសម្ព័ន្ធដូចតទៅ :

១-ថ្នាក់កណ្ដាល

១.១-ទីស្តីការក្រសួង

ក- ខុទ្ទកាល័យ

ខ- អគ្គាធិការដ្ឋាន

គ- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

ឃ- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

១.២_គ្រឹះស្ថានក្រោមការគ្រប់គ្រងរបស់ក្រសួង មានឋានៈស្មើនាយកដ្ឋាន

១_ មន្ទីរពេទ្យព្រះបាទនរោត្តម សីហនុ
២_ មន្ទីរពេទ្យព្រះកុសមៈ
៣_ មន្ទីរពេទ្យព្រះអង្គឌួង
៤_ មន្ទីរពេទ្យគន្ធបុប្ផា
៥_ មន្ទីរពេទ្យកុមារជាតិ
៦_ មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព
៧_ មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក
៨_ មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និង ហង់សិន
៩_ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
១០_ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ
១១_ មជ្ឈមណ្ឌលជាតិផ្តល់ឈាម
១២_ ឃ្លាំងឱសថកណ្តាល
១៣_ មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ
១៤_ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ
១៥_ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ

១.៣_គ្រឹះស្ថានសាធារណៈ មានឧបនិស្ស័យរដ្ឋបាលដែលនៅក្រោមអាណាព្យាបាលរបស់ក្រសួង

_មន្ទីរពេទ្យកាល់ម៉ែត

១.៤_គ្រឹះស្ថានសាធារណៈ មានឧបនិស្ស័យសេដ្ឋកិច្ចដែលនៅក្រោមអាណាព្យាបាលរបស់ក្រសួង

_សហគ្រាសផលិតឱសថកម្ពុជា

១.៥_សកលវិទ្យាល័យវិទ្យាសាស្ត្រ សុខាភិបាល ដែលមានអង្គភាពចំណុះ

_មហាវិទ្យាល័យវេជ្ជសាស្ត្រ
_មហាវិទ្យាល័យឱសថសាស្ត្រ
_មហាវិទ្យាល័យទន្តសាស្ត្រ

–សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

១.៦–គ្រឹះស្ថានដែលមានបេសកកម្មខាងសេវាសាធារណៈ ក្នុងក្របខ័ណ្ឌ អនុសញ្ញា គឺ វិទ្យាស្ថានប៉ាស្ទ័រ ។

២–អង្គភាពមូលដ្ឋាន

មន្ទីរសុខាភិបាលខេត្ត–ក្រុង និង រាជធានី

អង្គការលេខរបស់ក្រសួងសុខាភិបាល ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា៥.– ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃ អនុក្រឹត្យ លេខ២០ អនក្រ–បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមាន យោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋ លេខាធិការដ្ឋាន ។

ជំពូក៤

អគ្គាធិការដ្ឋាន

មាត្រា៦.– អគ្គាធិការដ្ឋានរបស់ក្រសួង សុខាភិបាល ទទួលបន្ទុក :

–ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមនិវាទក្រសួងសុខាភិបាល ។

–ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការ កិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

–ប្រតិបត្តិការកិច្ចតាមកាលដែលរដ្ឋមន្ត្រី បានប្រគល់ទុកចិត្ត

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយ ឬច្រើន រូបជួយធ្វើការទៅតាមការចាំបាច់ ។

ជំពូក ៥

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

មាត្រា៧.– អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ទទួលបន្ទុក

–គ្រប់គ្រងនិងដឹកនាំនាយកដ្ឋានចំណុះនានា ។

–សំរបសំរួលបណ្ដុំសកម្មភាពដឹកនាំរបស់អង្គភាពចំណុះក្រសួងជាមួយនិងអង្គភាពដទៃទៀត ដែលជាប់ព័ន្ធនឹងថវិកាហិរញ្ញវត្ថុ គណនេយ្យ រដ្ឋបាល និង បុគ្គលិក ។

–សិក្សាវាយតម្លៃ ជួយសំរួល តម្លើងឋានៈ ឬលើកទឹកចិត្តដល់អង្គភាព ឬបុគ្គលដែលនៅក្រោមអាណាព្យាបាលក្រសួង ។

មាត្រា៨.– អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយរូប ឬច្រើនរូបជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះ ចំនួន ០៣ គឺ :

–នាយកដ្ឋានរដ្ឋបាល

–នាយកដ្ឋានបុគ្គលិក

–នាយកដ្ឋានត្រួតពិនិត្យ និង ហិរញ្ញវត្ថុ

–នាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុ

មាត្រា៩.– នាយកដ្ឋានរដ្ឋបាល ទទួលបន្ទុក :

–សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្ដាល និង រវាងថ្នាក់កណ្ដាល និង អង្គភាពមូលដ្ឋានក្រោមឱវាទ ។

–គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

–ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

–សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

មាត្រា១០: នាយកដ្ឋានគ្រប់គ្រងបុគ្គលិក ទទួលបន្ទុក :

–គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និង ភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

-រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។

-ធ្វើកម្មវិធីពីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពតិមានប្រតិបត្តិ ។

-រៀបចំការងារបៀវត្សពលកម្ម ប្រាក់កំរៃ និងរបបឧបត្ថម្ភគោលនយោបាយសង្គម។

មាត្រា១១.- នាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុ ទទួលបន្ទុក :

-លើកគំរោងថវិកាក្រសួង និង តាមដានរំលឹកពីការប្រតិបត្តិ ។

-ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

-ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា ។

-ការតាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។

-ប្រមូលផ្តុំ និង សំរបសំរួលរាល់ការចំណាយរបស់ក្រសួង ។

-គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

-ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គូសផ្គុលសំភារៈ និង បរិក្ខាររបស់ក្រសួង ។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

-គ្រប់គ្រងយានដ្ឋាន និង យានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និង បែងចែកប្រេងឥន្ធនៈ និង គ្រឿងបន្លាស់ ។

-ទទួលនិងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាព ខេត្ត-ក្រុងនានា ។

-កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និង គណនេយ្យបធាតុ ។

-ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

-ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ ។

ជំពូក ៦

អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

មាត្រា១២.- អគ្គនាយកដ្ឋានសុខាភិបាល ទទួលបន្ទុក :

-រៀបចំ និង ដាក់អោយអនុវត្តនូវនយោបាយ និង យុទ្ធសាស្ត្រសុខាភិបាល សំដៅជួយអង្គភាពនានាអោយមានគុណភាព ទាំងផ្នែកការពារ និងទាំងផ្នែកព្យាបាលជំងឺ ដើម្បីលើកកំពស់សុខភាពប្រជាពលរដ្ឋជាទូទៅ ។

-សំរបសំរួលអង្គភាពសុខាភិបាលនានា មានសាធារណៈ និងឯកជន ។

-គ្រប់គ្រងបណ្តាកម្មវិធីសុខាភិបាលរបស់ជាតិ ។

-ដឹកនាំ និងគ្រប់គ្រងបណ្តាអង្គភាពសុខាភិបាលសាធារណៈ ។

-រៀបចំផែនការអភិវឌ្ឍន៍ តាមឯកទេស និង តាមបច្ចេកទេសសុខាភិបាល ។

-ធ្វើទំនាក់ទំនង និង សំរបសំរួលជំនួយអន្តរជាតិ សំដៅធ្វើអោយរីកចំរើនវិស័យសុខាភិបាល ។

-គ្រប់គ្រងសុវត្ថិភាពចំណីអាហារ ។

អគ្គនាយកដ្ឋានសុខាភិបាល មានការិយាល័យទំនាក់ទំនងអន្តរជាតិមួយ ជួយធ្វើការមានដែលមុខការធ្វើកម្មវិធី និង រៀបចំជំនួយបច្ចេកទេសដូចជា :

-ស្រាវជ្រាវរកហិរញ្ញប្បទាន ។

-សំរបសំរួលសកម្មភាពជំនួយទ្វេភាគី ពហុភាគី និង អន្តរជាតិ ។

-ពិនិត្យមើលពីលើបេសកកម្មរបស់ជំនាញការ ទីប្រឹក្សា ។

-ធ្វើទំនាក់ទំនងជាមួយបណ្តាអង្គការតាមភូមិភាគ និង អន្តរជាតិ ។

មាត្រា១៣.-អគ្គនាយកដ្ឋានសុខាភិបាល ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករង មួយ ឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានសុខាភិបាល មាននាយកដ្ឋានចំណុះ ដូចខាងក្រោម :

-នាយកដ្ឋានផែនការ និង ពត៌មានសុខាភិបាល

-នាយកដ្ឋានការពារសុខភាព

-នាយកដ្ឋានមន្ទីរពេទ្យ

-នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និង គ្រឿងសំអាង

-នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

មាត្រា១៤.- នាយកដ្ឋានផែនការ និង ពត៌មានសុខាភិបាល ទទួលបន្ទុក :

-ពង្រីកនយោបាយសុខាភិបាល រៀបចំផែនការសុខាភិបាល និងតាមដានរំលឹកការអនុវត្តន៍ការងារនេះ ។

- ប្រមូលផ្តុំពត៌មាន ស្ថិតិ និង ស្រាវជ្រាវពីសេដ្ឋកិច្ចនៃសុខាភិបាលដើម្បីរៀបចំនយោបាយ និង យុទ្ធសាស្ត្រសុខាភិបាល ។
- ផ្សព្វផ្សាយឯកសារវិទ្យាសាស្ត្រ និង បច្ចេកទេស ។
- រៀបចំការបោះពុម្ពរបាយការណ៍ផ្សេងៗ ។
- សិក្សានិងវាយតម្លៃ ទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកសេដ្ឋកិច្ចលើគំរោងការខាងវិនិយោគដែលមានប្រភពចំណាយក្នុងប្រទេស ឬ ក្រៅប្រទេស ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍វិស័យសុខាភិបាល ។

មាត្រា១៥.– នាយកដ្ឋានការពារសុខភាព ទទួលបន្ទុក :

- ធ្វើការកែសំរួលអោយទាន់សភាពការណ៍នូវសកម្មភាពនៃកម្មវិធីសុខភាពសាធារណៈ ។ វាយតម្លៃកម្មវិធីទាំងនោះ លើកិរិតលទ្ធផល និងលើផលប៉ះពាល់ដើម្បីគាំពារសុខភាពប្រជាពលរដ្ឋ ជាពិសេសសុខភាពមាតា និងទារក ។
- តាមដាន ត្រួតពិនិត្យ ស្រាវជ្រាវជំងឺរាំរ៉ៃ ដែលមិនឆ្លង ។
- គិតគូរពីនយោបាយសមស្រប រៀបចំអត្ថបទបទបញ្ញត្ត និង សំរបសំរួលកម្មវិធីអប់រំសុខភាព នីតិសម្បទាខាងឃោសនា អនាម័យ ។ សំរាប់ការងារនេះ នាយកដ្ឋានរៀបចំធ្វើអង្កេតខាងឃោសនា និងលើកកំពស់កំរិតផ្សព្វផ្សាយណែនាំឱវាទផ្សេងៗនៅតាមបណ្តាប្រព័ន្ធសុខាភិបាល ។
- សំរបសំរួលការងារអប់រំសុខភាពអនាម័យ និង ចត្តាឡីស័ក ។
- សំរបសំរួលការសិក្សា ស្រាវជ្រាវរកវិធានការណ៍បង្ការ និង លើកកំពស់សុខភាពប្រជារាស្ត្រ ។
- ធ្វើយុទ្ធនាការបញ្ចូលវ៉ាក់សាំង ។

មាត្រា១៦.– នាយកដ្ឋានមន្ទីរពេទ្យទទួលបន្ទុក :

- រៀបចំអត្ថបទ និង ដាក់អោយអនុវត្តបទបញ្ញាក្នុងការគ្រប់គ្រងសេវា ដើម្បីលើកកំរិតគុណភាព អង្គភាពវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ទន្តសាស្ត្រ ។
- តាមដានត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍របស់អង្គភាពថែទាំ អង្គភាពព្យាបាលវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ទន្តសាស្ត្រ ទាំងផ្នែកសាធារណៈ និងឯកជន ។
- រៀបចំ តាមដាន និង ត្រួតពិនិត្យអង្គភាពផ្តល់ឈាម ។

-ទទួល និង តម្កើងបរិក្ខារមន្ទីរពេទ្យ ។

-រៀបចំ និងធ្វើកម្មវិធីថែរក្សាបរិក្ខារមន្ទីរពេទ្យទាំងនោះ ។

-តាក់តែង និង ចុះបញ្ជីរាល់ថ្ងៃ ពីការផ្គត់ផ្គង់មន្ទីរពេទ្យ ។

-រៀបចំ និង ដាក់អោយអនុវត្តប្រព័ន្ធកម្មវិធីសំរាប់ការងារថែទាំជំងឺ ។

មាត្រា១៧.-នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ទទួលបន្ទុក :

-ធ្វើផែនការ និងត្រួតពិនិត្យត្រួតត្រាលើការបណ្តុះបណ្តាលជាមូលដ្ឋានពី បច្ចេកទេស សុខាភិបាលគ្រប់ផ្នែក ។

-ចូលរួមកំណត់ចំនួនមន្ត្រីដែលត្រូវបណ្តុះបណ្តាល ។

-រៀបចំគំរោងផែនការបណ្តុះបណ្តាលដល់មន្ត្រីរាជការសុខាភិបាល ដើម្បីបង្កើនកំរិតបច្ចេកទេសវេជ្ជសាស្ត្រគ្រប់ផ្នែក ស្របតាមតំរូវការ និងគោលនយោបាយរបស់ក្រសួង ។

-វាយតម្លៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

-សំរបសំរួលកម្មវិធីសិក្សា នៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងគ្រប់សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ ។

-សំរបសំរួលកម្មវិធីសិក្សានានា មានកម្មសិក្សា និង វិក្រឹតការផ្សេងៗ ។

-តាមដាន និងវាយតម្លៃសមត្ថភាពវិជ្ជាជីវៈសុខាភិបាល ។

មាត្រា១៨.-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និង គ្រឿងសំអាង ទទួលបន្ទុក :

-រៀបចំ និង អនុវត្តនយោបាយជាតិ ស្តីពីការងារឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ។

-រៀបចំអត្ថបទគតិយុត្ត សំរាប់ការគ្រប់គ្រង ការត្រួតពិនិត្យលើផលិតផល ការដាក់លក់លើទីផ្សារ និងការប្រើប្រាស់ឱសថ និង សំភារៈពេទ្យ ។

ក-ចំពោះឱសថ :

-រៀបចំគំរោងផែនការពីតំរូវការចាំបាច់ប្រើប្រាស់ឱសថសំរាប់អង្គភាពសាធារណៈ

-រៀបចំ និង ពិនិត្យទំរង់បែបបទសុំធ្វើអាជីវកម្មឱសថ ។

-សំរបសំរួលការទទួលជំនួយជាឱសថពីអង្គការនានា ។

-ត្រួតពិនិត្យគុណភាពឱសថ ដើម្បីអោយអតិថិជនប្រើប្រាស់ក្នុងតម្លៃ និង គុណភាពដ៏ប្រសើរ ។

-រៀបចំ និង ពិនិត្យបែបបទចុះបញ្ជីការ និងផ្តល់ទិដ្ឋាការឱសថ ។

ខ-ចំពោះចំណីអាហារ :

-រៀបចំ និង ពិនិត្យបែបបទសុវត្ថិភាពចំណីអាហារ ។

គ-ចំពោះគ្រឿងសំអាង :

-រៀបចំ និង ពិនិត្យបែបបទសុវត្ថិភាពគ្រឿងសំអាង ។

ឃ-ចំពោះសំភារៈបរិក្ខារពេទ្យ :

-រៀបចំគំរោងផែនការ ពីតំរូវការចាំបាច់ក្នុងការប្រើប្រាស់សំភារៈបរិក្ខារពេទ្យ របស់អង្គភាពសាធារណៈ ។

-រៀបចំ និង ពិនិត្យទំរង់បែបបទសុំធ្វើអាជីវកម្មសំភារៈបរិក្ខារពេទ្យ ។

-សំរបសំរួលការទទួលសំភារៈបរិក្ខារពេទ្យពីអង្គការនានា

មាត្រា១៩.- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ទទួលបន្ទុក :

-រៀបចំ និងដាក់អោយអនុវត្តនយោបាយ និង គោលការណ៍ណែនាំក្នុងការអនុវត្តន៍ សកម្មភាព ដើម្បីកាត់បន្ថយជំងឺឆ្លងគ្រប់ប្រភេទ ។

-តាមដាន និងវាយតម្លៃសកម្មភាពការងារអង្កេតវេជ្ជសាស្ត្រ និង សិក្សាស្រាវជ្រាវជំងឺឆ្លងគ្រប់ប្រភេទ ។

-រៀបចំ និង ដាក់អោយអនុវត្តផែនការជាតិប្រយុទ្ធនឹងជំងឺឆ្លងគ្រប់ប្រភេទ ។

មាត្រា២០.-អង្គភាពថ្នាក់កណ្តាលដែលស្ថិតនៅក្នុងចំណុច ១.២ និង ១.៤ នៃមាត្រា៤ ត្រូវអនុវត្តតាមមុខជំនាញឯកទេសរបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យ ។

មាត្រា២១.-ការគ្រប់គ្រងផ្នែករដ្ឋបាល និងបច្ចេកទេសនៅវិទ្យាស្ថានប៉ាស្ទ័រ ត្រូវអនុវត្តស្របតាមកិច្ចព្រមព្រៀងរវាងភាគីក្រសួងសុខាភិបាល និងវិទ្យាស្ថានប៉ាស្ទ័រទីក្រុងប៉ារីស ។

ជំពូក ៧

អង្គភាពមូលដ្ឋាន

មាត្រា២២.-នៅតាមបណ្តាខេត្ត-ក្រុងនីមួយៗ មានមន្ទីរសុខាភិបាលខេត្ត-ក្រុងមួយដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។

ជំពូក ៨

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា២៣.–អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយ ថវិកាក្នុងបណ្តាក្រសួង ។

ជំពូក ៩

អវសានប្បញ្ញត្តិ

មាត្រា២៤.–ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា២៥.–បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២៦.–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា២៧.–អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

****

អង្គការលេខរបស់ក្រសួងសុខាភិបាល



អនុក្រឹត្យ លេខ ៦៨ អនក្រ.បក
ស្តីពីការផ្ទេរឥណទាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស /៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខនស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែក ឥណទានផ្ទៃក្នុងជំពូកនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧
- បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និង ចំណាយថវិកាតាម

ប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៤ និង ប្រកាសស្ដីពីការកែប្រែ និង បំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី០៧ ខែ មិនា ឆ្នាំ ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥, លេខ៣២៣ ប្រ.សហវ.ថ ចុះ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥, លេខ៣៣៦ ប្រ.សហវ.ថ ចុះ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ១៩៩៥ លេខ ០៧១ ប្រ.សហវ.ថ ចុះ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និង លេខ ៨០១ សហវ.ថ. ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

–តាមសំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា១.–ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន ៦២២ លានរៀល (ប្រាំមួយរយម្ភៃពីរលានរៀល) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មក... ៣១ របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ។

មាត្រា២.–ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ដោះស្រាយគោលនយោបាយដល់ប្រជាពលរដ្ឋ ដែលតំរូវអោយរុះរើលំនៅដ្ឋានចាកចេញពីប៉ូរីកីឡា ។

មាត្រា៣.–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២០២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១០៩៤/៨៤ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/០៨៩៧/១៨៦ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បើតាមសំណើរបស់ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១.– តែងតាំងលោក **ថៅ ស៊ីថុន** ជានាយករងខុទ្ទកាល័យ ជំនួសលោក **ផ្លុង គីមឆុន**

មាត្រា២.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យលេខ ២០៣ អនក្រ.តត

ស្តីពីការតម្លើងឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា១.– ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ [illegible] នាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ [illegible] ១១០៦៣២ លេខាឯកឧត្តម [illegible] នាយអគ្គសេនាធិការ បច្ចុប្បន្នជា នាយការិយាល័យអគ្គនាយកដ្ឋានយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតប្រចាំនៅព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា២.– [illegible] សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ [illegible] ត្រូវអនុវត្ត

អនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

...

អនុក្រឹត្យ លេខ ២០៥ អនក្រ.តត

ស្តីពីការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

===

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា

–យោងតាមសំណើលេខ ០១ សណបល/៩/៩៧ ចុះថ្ងៃទី ២៩_៩_៩៧ របស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ស្តីពីការរៀបចំសេនានុព័ន្ធយោធា ប្រចាំព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា១._ត្រូវបានតែងតាំងមុខងារនាយទាហានសេនានុព័ន្ធយោធាប្រចាំព្រះរាជាណាចក្រ ថៃឡង់ដ៍ ដែលមានរាយនាមដូចខាងក្រោម ÷

១_លោក វរសេនីយ៍ឯក **ង៉ាន សាវ៉ន** អត្តលេខ ០០០៦៣២ ជានាយការិយាល័យ

សេនានុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

២_លោក វរសេនីយ៍ទោ ទៀង **លីសក្តិ** អត្តលេខ ០០០៥៧២ ជានាយរងការិយាល័យសេនានុព័ន្ធយោធា អមស្ថានទូតប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ មានឋានៈស្មើនាយការិយាល័យសេនានុព័ន្ធយោធា

៣_លោក អនុសេនីយ៍ទោ ម៉ៅ **ចិមុល** អត្តលេខ ០១៤១០២ ជាជំនួយការបុគ្គលិករដ្ឋបាល និងបច្ចេកទេសសេនានុព័ន្ធយោធា ប្រចាំព្រះរាជាណាចក្រ ថៃឡង់ដ៍ ។

មាត្រា២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ២០៥ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

—

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/... ចុះថ្ងៃទី ... ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- ពិនិត្យឃើញពីភាពចាំបាច់ [illegible] និង [illegible] របស់មន្ត្រីក្នុង [illegible]

សម្រេច

មាត្រា ១.- ត្រូវបានតែងតាំងលោកស្រី [illegible] ជាជំនួយការ [illegible] ទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើប្រធាននាយកដ្ឋាន ក្នុងបន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- សហការីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ [illegible] តាមភារកិច្ចរៀងៗខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ២០៦ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា១.– តែងតាំងលោក **តន់ យ៉ាន** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន ។

មាត្រា២.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងចំ

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧.

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អត្ថិប្បវេណីទិនត្រា

អ៊ឹង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ២០៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

===

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា១.-តែងតាំងមន្ត្រីក្រសួងពាណិជ្ជកម្ម មានឋានៈប្រធាននាយកដ្ឋាន ចំនួន ១២រូប ដូចមានឈ្មោះខាងក្រោម :

ក-អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ :

១-លោក **សួស ចណ្ណា**	បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានបុគ្គលិក ជាប្រធាន នាយកដ្ឋានបុគ្គលិក
២-លោកស្រី **ឡៅ្រ៊ន សារ៉ាត់**	បច្ចុប្បន្ន អនុប្រធានមន្ទីរ ជាប្រធាន នាយកដ្ឋាន រដ្ឋបាល
៣-លោក **រស់ នឹមសារុន**	បច្ចុប្បន្ន អនុប្រធានមន្ទីរ ជាប្រធាន នាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ

ខ-អគ្គនាយកដ្ឋានបច្ចេកទេស :

១-លោក **យី គឹមសេង**	បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានផែនការ ជាប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

២_លោក អ៊ុយ សុខារាត្ន — បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានពាណិជ្ជកម្ម ក្រៅប្រទេស ជាប្រធាននាយកដ្ឋាន ពាណិជ្ជកម្ម ក្រៅប្រទេស

៣_លោក ម៉ូ សារ៉ាន់ — បច្ចុប្បន្ន ប្រធានការិយាល័យនីតិកម្ម ជាប្រធាននាយកដ្ឋាននីតិកម្ម

៤_លោក ម៉ក់ ពេជ្ររិទ្ធី — បច្ចុប្បន្ន អនុប្រធានមន្ទីរ ជាប្រធាន នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

៥_លោក ឈី ផាណ្ណា — បច្ចុប្បន្ន អនុប្រធាននាយកដ្ឋានពាណិជ្ជកម្ម ក្រៅប្រទេស ជាប្រធាននាយកដ្ឋាន កម្មសិទ្ធិបញ្ញា

៦_លោក ពេជ រិទ្ធី — បច្ចុប្បន្ន ប្រធានការិយាល័យអាស៊ាន ជា [illegible]នាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ

៧_លោក ប្រាក់ នក — បច្ចុប្បន្ន អនុប្រធានក្រុមហ៊ុនកម្ពុជានីហរណ៍ អាហរណ៍និងបែងចែកជាប្រធាននាយកដ្ឋាន ជំរុញការនាំចេញ

គ_អគ្គាធិការដ្ឋាន :

១_លោក ស៊ុំ សារ៉ាញ់ — បច្ចុប្បន្ន អនុប្រធានគណៈកម្មការត្រួតពិនិត្យ ជាអធិការរដ្ឋបាលនិងបច្ចេកទេស ថ្នាក់ស្មើ ប្រធាននាយកដ្ឋាន

២_លោក ចិន យ៉ាណ្ណា — បច្ចុប្បន្ន អនុប្រធានក្រុមហ៊ុនកម្ពុជានីហរណ៍ អាហរណ៍ និងបែងចែក ជាអធិការគណ នេយ្យហិរញ្ញវត្ថុ [illegible] មានឋានៈស្មើប្រធាន នាយកដ្ឋា[illegible]

មាត្រា២._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី [illegible]ពាណិជ្ជកម្ម រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន ដែលមានការពា[illegible]ន្ធ និង សាមីខ្លួន ដូចមាន

ចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ២០៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

= = =

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា១._តែងតាំងមន្ត្រីក្រសួងពាណិជ្ជកម្ម ថ្នាក់អគ្គនាយករង ចំនួន ៤រូប និងថ្នាក់អគ្គាធិការរងចំនួន ១រូប ដូចមានឈ្មោះខាងក្រោម :

១_លោក **ទ៉ា ខាង** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២_លោក **កែ ផៃ** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៣_លោក **ខ៊ាន់ អៃ** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស

៤_លោក **ឈួន ជាវ៉ា** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស

៥_លោក **គីម ធឿន** ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋាន

មាត្រា២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន ដែលជាប់ការពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

អនុក្រឹត្យ លេខ ២០៩ អនក្រ.តត

ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ

= = =

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងមាត្រា ៦៣ ជំពូកទី១០ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមយោបល់ឯកភាពរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

មាត្រា១.- យល់ព្រមពន្យារពេលចូលនិវត្តន៍ ចំនួន ០១ឆ្នាំ តទៅទៀត សំរាប់លោក **ឡាក់ ឡេខ** ប្រធានមន្ទីរនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយគិតចាប់ពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៧ ដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៨ ។

មាត្រា២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការនៃរដ្ឋ

លេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងលោក ច្បាស់ ខ្សោយ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

២_សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៣៩ សសរ

ស្តីពីការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា

===

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤/៨៣ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល

–យោងតាមសំណើក្រសួងការបរទេស ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៧

សំរេច

ប្រការ១.– បង្កើតគណៈកម្មការមួយមានឈ្មោះថា «គណៈកម្មការជាតិ យូណេស្កូកម្ពុជា» ដែលមានសមាសភាពដូចតទៅ ÷

១–ឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២–ឯកឧត្តម **អ៊ុច ស៊ាន** អនុរដ្ឋលេខាធិការក្រសួងការបរទេស តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការ

៣–លោក **យ៉ង់ យ៉ារណូ** អនុប្រធានមន្ទីរក្រសួងអប់រំ តំណាងក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការរង

៤–លោក **ជុច គឿន** សកលវិទ្យាធិការរង ក្រសួងវប្បធម៌ និងសិល្បៈ តំណាងក្រសួងវប្បធម៌និងសិល្បៈ អគ្គលេខាធិការរង

៥–លោក **មួង សុទត្ថ** ប្រធាននាយកដ្ឋាន ក្រសួងពត៌មាន តំណាងក្រសួងពត៌មាន សមាជិក

ប្រការ២.–គណៈកម្មការជាតិ យូណេស្កូកម្ពុជា មានភារកិច្ចដូចតទៅ ÷

–ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹងយូណេស្កូ និង កម្មវិធីរបស់យូណេស្កូ ។

–មានតួនាទីជាភ្នាក់ងារទាក់ទង រវាងយូណេស្កូ ជាមួយក្រសួង ស្ថាប័ន អង្គការ និង បុគ្គលនានាដែលយកចិត្តទុកដាក់បំពេញការងារ ដើម្បីជំរុញអោយមានការរីកចំរើនផ្នែកអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និង ពត៌មាននៅកម្ពុជា ។

–ធានានូវការចូលរួមយ៉ាងសកម្មរបស់កម្ពុជា ក្នុងកម្មវិធីចូលរួមជាមួយគ្នារបស់យូណេស្កូ ដោយធ្វើការសំរបសំរួលជ្រើសរើសគំរោងអាទិភាពទាំងឡាយ រៀបចំដោយក្រសួង និង ស្ថាប័នពាក់ព័ន្ធនានា ។

–ជួយរាជរដ្ឋាភិបាលក្នុងការសំរបសំរួលជាមួយក្រសួង ស្ថាប័ន និង អង្គការពាក់ព័ន្ធនានា អំពីការជ្រើសរើសបេក្ខជនសំរាប់កម្មវិធីអាហារូបករណ៍ ។

-ជួយរដ្ឋាភិបាលក្នុងការរៀបចំ និងការចូលរួមសម័យប្រជុំសន្និសីទទូទៅ និង ការប្រជុំអន្តររដ្ឋាភិបាលផ្សេងៗទៀតដែលរៀបចំដោយយូណេស្កូ ។

-ជំរុញ និង ពង្រីកទំនាក់ទំនងជាមួយគណៈកម្មការជាតិយូណេស្កូផ្សេងទៀត ជាពិសេសជាមួយគណៈកម្មការជាតិយូណេស្កូនៅក្នុងតំបន់ជាមួយគ្នា និងចូលរួមជាមួយគណៈកម្មការទាំងនោះ ក្នុងកម្មវិធីរួមគ្នា និង សិក្សាអំពីបញ្ហាទាំងឡាយ ដែលមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា ។

-បំពេញករណីយកិច្ចដទៃទៀត ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធដល់គណៈកម្មការយូណេស្កូកម្ពុជា និង គណៈកម្មការយូណេស្កូតំបន់ និង យូណេស្កូរួម ។

ប្រការ៣.-គណៈកម្មការជាតិមានសិទ្ធិរៀបចំមហាសន្និបាតយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដឹកនាំដោយប្រធាន ឬ អនុប្រធាន និងការប្រជុំដទៃទៀតតាមការយល់ឃើញរបស់ប្រធាន ឬតាមការស្នើសុំពីសមាជិកភាគច្រើនរបស់គណៈកម្មការជាតិ ។

មហាសន្និបាតមានភារកិច្ច :

-អនុម័តរបាយការណ៍ប្រចាំឆ្នាំ ណែនាំ និង ចាត់វិធានការចំពោះអភិវឌ្ឍន៍កម្មវិធី និង សកម្មភាពរបស់គណៈកម្មការជាតិយូណេស្កូបន្តទៅមុខទៀត ។

-លើកសំណើអំពីការជ្រើសរើសសមាសភាពគណៈប្រតិភូកម្ពុជា ទៅចូលរួមសន្និសីទទូទៅ របស់ យូណេស្កូ ជូនរាជរដ្ឋាភិបាល ។

ប្រការ៤.-គណៈកម្មការជាតិយូណេស្កូកម្ពុជា មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួនទៀត និងលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដើម្បីអនុវត្តការងារ ។ តួនាទី និង ភារកិច្ចរបស់អនុគណៈកម្មការ និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយឡែក ដោយគណៈកម្មការជាតិយូណេស្កូកម្ពុជា ។

ប្រការ៥.-គណៈកម្មការជាតិយូណេស្កូកម្ពុជា មានទីស្នាក់ការបណ្តោះអាសន្ននៅទីស្នាក់ការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

ប្រការ៦.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ន ឯកឧត្តម ដូច

ប្រការ១ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៤០ សសរ

ស្តីពីការផ្គត់ផ្គង់ភស្តុភារ សំភារៈ បរិក្ខារ គ្រប់ប្រភេទ និងសំលៀកបំពាក់ឯកសណ្ឋាន សំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងជីវពល និងកងនគរបាលជាតិ និងសំភារៈបរិក្ខារពេទ្យ សំរាប់មន្ទីរពេទ្យ ជូនក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ

= = =

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកលើបទពិសោធន៍ល្អនៃការងារផ្គត់ផ្គង់ ភស្តុភា សំភារៈ បរិក្ខារ គ្រប់ប្រភេទ និងសំលៀកបំពាក់ឯកសណ្ឋាន សំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ

ជាតិ កងជីវពល និងកងនគរបាលជាតិ និងសំភារៈបរិក្ខារពេទ្យ សំរាប់មន្ទីរពេទ្យ ជូនក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ របស់ក្រុមហ៊ុនស្វូតីម៉ិចកន្លងមក

–ក្នុងគោលដៅអនុវត្តគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំពោះក្រុមហ៊ុនឯកជនក្នុងស្រុក

–យោងតាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ១៩៩៧ និងការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី១០ ខែ តុលា ឆ្នាំ១៩៩៧

សំរេច

ប្រការ១.– អនុញ្ញាតនិងប្រគល់សិទ្ធិ អោយក្រុមហ៊ុន ស្វូតីម៉ិច ក្នុងការធានាផ្គត់ផ្គង់ ភស្តុភារ សំភារៈ បរិក្ខារគ្រប់ប្រភេទ និងសំលៀកបំពាក់ឯកសណ្ឋាន សំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងជីវពល និងកងនគរបាលជាតិ និងសំភារៈបរិក្ខារពេទ្យ សំរាប់មន្ទីរពេទ្យ ជូនក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

–ក្នុងករណីក្រុមហ៊ុនស្វូតីម៉ិចអស់លទ្ធភាពក្នុងការផ្គត់ផ្គង់មុខទំនិញខាងលើ នោះ ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ នសិទ្ធិទាក់ទងជាមួយក្រុមហ៊ុនផ្សេងទៀត ដើម្បីផ្គត់ផ្គង់ជូនតាមសភាពជាក់ស្តែង ។

ប្រការ២.– ចំពោះថ្លៃផ្គត់ផ្គង់ភស្តុភារ សំភារៈ បរិក្ខារគ្រប់ប្រភេទ និងសំលៀកបំពាក់ឯកសណ្ឋាន ព្រមទាំងសំភារៈបរិក្ខារពេទ្យ ដែលចែងក្នុងប្រការ១ ខាងលើនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិគ្រោះថ្លៃជាមួយក្រុមហ៊ុន ស្វូតីម៉ិច តាមតំណាក់កាលនីមួយៗជាបន្តបន្ទាប់អោយបានត្រឹមត្រូវ ។

ប្រការ៣.– សេចក្តីជូនដំណឹងលេខ ១២៣ សជណ.សរ. ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីអំពីការផ្គត់ផ្គង់ឯកសណ្ឋាន និង សំភារៈបរិក្ខារជូនកងកំលាំងនគរបាលជាតិសំរាប់ឆ្នាំ ១៩៩៧–១៩៩៨ ត្រូវបន្តអនុវត្តរហូតដល់ចប់ឆ្នាំ ១៩៩៨ ។ ក្រោយឆ្នាំ ១៩៩៨ ក្រុមហ៊ុនទាំងបី (ក្រុមហ៊ុនសោមសុផល ក្រុមហ៊ុនដួងឈីវ និងក្រុមហ៊ុន គួហ៊្វឡុង) ត្រូវពិភាក្សា សំរបសំរួលជាមួយក្រុមហ៊ុនស្វូតីម៉ិច ក្នុងករណីក្រុមហ៊ុនណាមានបំណងធ្វើបន្តទៀត ។

ប្រការ៤.– បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៥.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនសូគីម៉ិច ក្រុមហ៊ុនសោមសុផល ក្រុមហ៊ុនដួងឈើវ និងក្រុមហ៊ុនគួហ៊្វុឡុង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៤១ សសរ

ស្តីពីការផ្ទេរសិទ្ធិ

\===

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

– តាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

សំរេច

ប្រការ១._ផ្ទេរសិទ្ធិជូន ឯកឧត្តម **ខាំ ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ និងជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៧ រហូតដល់ពេលឯកឧត្តម **គាត ឈន់** វិលត្រឡប់មកវិញ ។

ប្រការ២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ខាំ ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

III- ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

១_ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ១៤៩ ប្រក.មស.

ស្តីពីការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះអនុក្រឹត្យ លេខ ៥៨ អនក្រ ចុះថ្ងៃទី០៣ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការផ្ទេរនាយកដ្ឋានសុរិយោដី ស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

–បានឃើញប្រកាសលេខ ០៩ ចុះថ្ងៃទី២៩–០១–៩៧ ស្តីពីការប្តូរឈ្មោះការិយាល័យសុរិយោដីខេត្ត–ក្រុង ទៅជាមន្ទីរសុរិយោដី ខេត្ត–ក្រុង

–យោងសំណើរបស់នាយកដ្ឋានសុរិយោដី

សំរេច

ប្រការ១.–ត្រូវបានតែងតាំងតម្លើងឋានៈមន្ត្រីរាជការដូចមានរាយនាមខាងក្រោម ÷

១–លោក **ស៊ឹម ម៉ុនឈឿន**	បច្ចុប្បន្នអនុប្រធានការិយាល័យសុរិយោដីខេត្ត ជាប្រធានការិយាល័យ សុរិយោដីខេត្តកោះកុង
២–លោក **ហុង យន**	បច្ចុប្បន្នមន្ត្រីការិយាល័យអធិការកិច្ចនៃនាយកដ្ឋានសុរិយោដី ជាអនុប្រធានការិយាល័យសុរិយោដីខេត្តកោះកុង
៣–លោក **គង់ សោភ័ណ**	បច្ចុប្បន្នមន្ត្រីការិយាល័យកិច្ចការថ្មីនៃនាយកដ្ឋានសុរិយោដី ជាប្រធានការិយាល័យសុរិយោដីខេត្តព្រះវិហារ
៤–លោក **ហួត ម៉ុនលីម**	បច្ចុប្បន្នមន្ត្រីការិយាល័យភូមិបាល ស្រុកដូនកែវ ជាប្រធានការិយាល័យភូមិបាលស្រុកដូនកែវ ខេត្តតាកែវ
៥–លោក **ស៊ិន សុខ**	បច្ចុប្បន្នប្រធានផ្នែកអភិរក្សមន្ទីរសុរិយោដីខេត្ត ជាប្រធានការិយាល័យភូមិបាល ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ប្រការ២.–ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានសុរិយោដី មន្ទីរសុរិយោដីខេត្តកោះកុង ខេត្តព្រះវិហារ ខេត្តតាកែវ .

ខេត្តកំពង់ឆ្នាំង ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
សុខ អាន

* * *

២_សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៧

សេចក្ដីសំរេច លេខ ១៧ សសរ

ស្ដីពីការតែងតាំងគណៈមេប្រយោគ

សំរាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ថ្នាក់មធ្យម

= = =

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ៤០ អនក្រ ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្ដីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញសេចក្ដីសំរេចលេខ ០៨ សសរ.សករ. ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៦ ស្ដីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការថ្នាក់មធ្យម

- បានឃើញលិខិតលេខ ១២២១ ស.ជ.ណ.ស.ក.រ. ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការទទួលស្គាល់បេក្ខជន ដែលអនុញ្ញាតអោយចូលធ្វើវិញ្ញាសាប្រឡងប្រជែងជ្រើសរើសមន្ត្រីមធ្យម
- បានឃើញសេចក្តីសំរេចលេខ ០១ ស.ស.រ.ស.ក.រ. ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការទទួលស្គាល់បេក្ខជនដែលអនុញ្ញាតអោយចូលធ្វើវិញ្ញាសាប្រឡងប្រជែងជ្រើសរើសមន្ត្រីមធ្យម
- យោងតាមព្រះរាជចំណារយល់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ១៩៩៦ និងចំណារយល់ព្រមសម្តេចនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦
- យោងលើស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- តាមសំណើរបស់នាយកសាលាភូមិន្ទរដ្ឋបាល

សំរេច

ប្រការ១.- វិញ្ញាសាសរសេរនៃការប្រឡងប្រជែងចូលសាលាភូមិន្ទរដ្ឋបាលសំរាប់មន្ត្រី ថ្នាក់មធ្យម នឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី១៦ ខែ តុលា និងថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ ១៩៩៧ ។

ប្រការ២.- គណៈមេប្រយោគនៃការប្រឡងប្រជែងចូលសាលាភូមិន្ទរដ្ឋបាល សំរាប់មន្ត្រីមធ្យម ឆ្នាំ ១៩៩៧ មានសមាជិកពេញសិទ្ធិ ៧ រូប :

- ឯកឧត្តម សុខ អាន	ប្រធាន
- ឯកឧត្តម លី គីមសុខ	អនុប្រធាន
- ឯកឧត្តម ណារី គាន់	សមាជិក
- ឯកឧត្តម ហេងវង្ស ប៊ុនឆាត	សមាជិក
- ឯកឧត្តម ប្រាក់ សុខ	សមាជិក
- ឯកឧត្តម ទេព ដារ៉ុង	សមាជិក
- ឯកឧត្តម ពៅ សាមី	សមាជិក

ប្រការ៣ : តំណាងជំនួយសំរាប់ពិគ្រោះយោបល់ :

-Maurice Gaillard	នាយកការសិក្សា
- ឯកឧត្តម ចែម វិឡា	តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម សារ៉ាក់ ខាន់ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-លោក ឡៅ ប៊ុនប៉ា តំណាងក្រសួងមហាផ្ទៃ
-លោក ពេជ សោភ័ណ្ឌ តំណាងក្រសួងអប់រំ យុវជននិងកីឡា
-លោក អ៊ុំ ជន តំណាងក្រសួងយុត្តិធម៌

ប្រការ៤ .-ក្នុងករណីដែលប្រធានមានធុរៈ មុខងាររបស់ប្រធានគណៈមេប្រយោគ ត្រូវអនុប្រធានជាអ្នកបំពេញ ។

ក្នុងករណីដែលសមាជិកណាមួយមានធុរៈ ប្រធានគណៈមេប្រយោគ ត្រូវតែងតាំងអ្នកជំនួស តាមសំណើរបស់នាយកសាលា ។

ប្រការ៥.-សមាជិកនៃគណៈកម្មការនានានៃវិញ្ញាសាសរសេរ ត្រូវតែងតាំងតាមសេចក្ដីសំរេចរបស់ប្រធានគណៈមេប្រយោគ តាមសំណើរបស់នាយកសាលា ។

ប្រការ៦.-គណៈកម្មការកំណែ វិញ្ញាសាសរសេរ និងដាក់ពិន្ទុវិញ្ញាសាសួរផ្ទាល់មាត់ មានសមាសភាព ដូចតទៅ ÷

ប្រធាន : ឯកឧត្តម សុខ អាន
អនុប្រធាន : ឯកឧត្តម លី គឹមសុខ

វិញ្ញាសាសរសេរ :

អត្ថាធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ : លី គឹមសុខ -ពៅ សាមី
ស្ថាប័ននយោបាយ ឬរដ្ឋបាល : ទេព ដារ៉ុង -ហេងវង្ស ប៊ុនឆាត
សេដ្ឋកិច្ចកម្ពុជា និង PNRD ឬច្បាប់ហិរញ្ញវត្ថុ : វ៉ាន់ ប៊ុនថេត -ប្រាក់ សុខ
ស្រី ឌី - សារ៉ាក់ ខាន់
បកប្រែអត្ថបទ បារាំង ឬ អង់គ្លេស : លឹម សុគន្ធ -សុក សារ៉េត
ថែម វិឡា - ស៊ុម សៀនប៉ាវ

វិញ្ញាសាផ្ទាល់មាត់ :

ភូមិសាស្ត្រកម្ពុជា និងអរិយធម៌ខ្មែរ : អ៊ូ វឡី - ស៊ុម សារ៉ាក់
សន្ទនាភាសាបារាំង ឬអង់គ្លេស : លឹម សុគន្ធ - ស៊ុម សៀនប៉ាវ
ចំណេះដឹងទូទៅ និងការសន្ទនាជាមួយគណៈមេប្រយោគ :
-សមាជិកពេញសិទ្ធិទាំង ៧ រូប

ប្រការ៧.–ផ្ទាន់ដែលអោយក្នុងនិកាសប្រឡងប្រជែងនឹងត្រូវគិតតាមតារាងអត្រាដែលមានបញ្ញត្តិ

ប្រការ៨.–នាយកសាលាភូមិន្ទរដ្ឋបាលត្រូវ ទទួលភារៈចាត់ការអោយបានសំរេចតាមសេចក្តីសំរេចនេះ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

សុខ អាន

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាស លេខ ៩៦៤ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧

= = =

សំរេច

ប្រការ១.–អនុញ្ញាតអោយក្រុមហ៊ុន ហ្គោលិន អង្គរស៊ីម៉ង់ត៍ (GOLDON ANGKOR CEMENT LTD) តំណាងដោយលោក TSUI HOI PAN សញ្ជាតិចិន (ហុងកុង) ភេទប្រុស អាយុ ៥០ឆ្នាំ អាស័យដ្ឋាន 2/F 751, Nathan Road KOWLOON – HONGKONG កាន់លិខិតឆ្លងដែន លេខ H00030768 ចុះថ្ងៃទី២៧-០៧..៩៧. និងលោក ណាង សុធី អាយុ ៥១ឆ្នាំ អាស័យដ្ឋានផ្ទះលេខ ៧ ផ្លូវលេខ ៦០៦ សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ កាន់អត្ត សញ្ញាណប័ណ្ណលេខ ២៦៦៤៣១ ភ.ព. ចុះថ្ងៃទី២.១០.៨៩. បង្កើតរោងចក្រ ផលិតស៊ីម៉ង់ត៍ « ដែលមានឈ្មោះថា » រោងចក្រផលិតស៊ីម៉ង់ត៍អង្គរមាស » មានទីតាំងស្ថិតនៅក្នុងភូមិដីរ៉ៃ ឃុំគីណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ។

ប្រការ២.–ក្រុមហ៊ុនត្រូវធ្វើការសាងសង់ និងរៀបចំគ្រឿងចក្រ ទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល២៤ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។ ការសាងសង់ត្រូវផ្តើមអនុវត្តយ៉ាងយូរបំផុត ក្នុងរយៈពេល០៦ខែ បន្ទាប់ពីថ្ងៃចេញប្រកាសនេះ ។

ប្រការ៣._ ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពលអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ៤._ រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «ស៊ីម៉ងត៍» ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៥._ ការយករ៉ែជាវត្ថុធាតុដើមសំរាប់ដំណើរការរោងចក្រនេះ ត្រូវអនុវត្តតាមកិច្ចសន្យា រវាងក្រុមហ៊ុន និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៦._ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ពូ សុធីរៈ

* * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២៧៨/៩៧/ពម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមតំរូវការចាំបាច់របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងថ្នាក់អនុប្រធាននាយកដ្ឋាន ចំនួន ០២រូប នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១_លោក **ម៉ូ វណ្ណារិទ្ធ** ជាអនុប្រធាននាយកដ្ឋាននិពន្ធក្នុងប្រទេស

២_លោក **សរ មុយលី** ជាអនុប្រធាននាយកដ្ឋាននិពន្ធក្រៅប្រទេស

ប្រការ២ : ឯកឧត្តម អគ្គនាយករដ្ឋបាល_ហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ អគ្គនាយកវិទ្យុជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារិទ្ធ

***

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២៧៩/៩៧/ពម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

...

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦/១៤/ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។

_តាមតម្រូវការចាំបាច់ របស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

_ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងលោក **ហែម ចន្ទវិទ្ធ** ជាប្រធានការិយាល័យផែនការគណនេយ្យ ហិរញ្ញកិច្ច អគ្គនាយកដ្ឋានទូរទស្សន៍ នៃក្រសួងពត៌មាន

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល_ហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ អគ្គនាយកវិទ្យុជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២៨១/៩៧/ពម.ប្រក

ស្តីពីការតែងតាំងមន្ត្រីក្រសួងពត៌មាន

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រម នស រកម /០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន

_យោងតាមតម្រូវការចាំបាច់

_ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការ ចំនួន ០៦នាក់ ជាថ្នាក់ប្រធាន អនុប្រធានការិយាល័យ នាយកដ្ឋានបុគ្គលិក អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម ៖

ក_ថ្នាក់ប្រធានការិយាល័យ

១_លោក **គង់ សុវណ្ណ**	ជាប្រធានការិយាល័យបុគ្គលិក
២_លោក **ម៉ូ សឿន**	ជាប្រធានការិយាល័យខេត្ត_ក្រុង
៣_កញ្ញា **ខាន់ ចន្ទវណ្ណា**	ជាប្រធានការិយាល័យកិច្ចការសង្គម

ខ_ថ្នាក់អនុប្រធានការិយាល័យ

១_លោក **សៀង វណ្ណថារ៉ា**	ជាអនុប្រធានការិយាល័យបុគ្គលិក
២_លោក **អ៊ុច ស៊ីថា**	ជាអនុប្រធានការិយាល័យបុគ្គលិក
៣_លោក **ឃួន សារម៉ឿន**	ជាអនុប្រធានការិយាល័យខេត្ត_ក្រុង

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល_ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ គ្រប់អគ្គនាយកដ្ឋានចំណុះ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុ និងសាមីខ្លួន ក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២៨៥/៩៧/ពម.ប្រក

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតសំណើសុំអនុញ្ញាតច្បាប់បង្កើតស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ខេត្តបាត់ដំបង លេខ៧០៧ ពមខ ចុះថ្ងៃទី ០៨.១០.១៩៩៧ របស់មន្ទីរពត៌មាន ខេត្តបាត់ដំបង ។

សំរេច

ប្រការ១ : អនុញ្ញាតអោយមន្ទីរពត៌មានខេត្តបាត់ដំបង បើកស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ខេត្តបាត់ដំបង CANAL 7 VHF ដែលមានកំលាំងផ្សាយ ១ KW និងកំពស់ អង់តែនត្រឹម ១២០ គត់ ហើយមានទីតាំងស្ថិតនៅទីរួមខេត្តបាត់ដំបង ។

ប្រការ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍នេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិបទបញ្ជា ឬ សេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : ក្នុងករណីមិនគោរពតាមកិច្ចសន្យា មន្ទីរពត៌មានខេត្តបាត់ដំបង ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ៤ : អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ_សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល_ហិរញ្ញវត្ថុ ក្រសួងពត៌មាន មន្ទីពត៌មានខេត្តបាត់ដំបងនិងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ៥ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ២៨៦/៩៧/៣ម.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

– បានឃើញព្រះរាជក្រម នស.រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន

– យោងតាមតម្រូវការចាំបាច់ របស់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា

– ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងលោក **គី ម៉ាលី** ជាអនុប្រធាននាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពតិមាន ។

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល–ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយកវិទ្យុជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ–ហិរញ្ញកិច្ច និងសាម៉ីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៧៤៤/អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបើកសាលា បឋមសិក្សា

ឯកជន អាត់ទេនទិស កម្ពុជា

\---

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត./០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ

– បានឃើញព្រះរាជក្រម លេខ សន/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា

– បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការបើកសាលារៀនចំនេះទូទៅឯកជន

– បានឃើញ ពាក្យស្នើសុំរបស់លោកស្រី អ៊ិន សម្បត្តិ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៦ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ១ : អនុញ្ញាតអោយលោកស្រី **អ៊ុន សម្បត្តិ** បើកសាលាបឋមសិក្សាឯកជន អាត់វេនទីសកម្ពុជា ដែលមានទីតាំងស្ថិតនៅផ្លូវ ៣១៤ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_៩៧ នេះតទៅ ។

ប្រការ២ : សាលាបឋមសិក្សាឯកជន អាត់វេនទីសកម្ពុជា ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សា តាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ៣ : លោកស្រី **អ៊ុន សម្បត្តិ** ត្រូវដឹកនាំ គ្រប់គ្រង ចាត់តាំង គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ៤ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា លោកប្រធាននាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធាននាយកដ្ឋានផែនការ_ហិរញ្ញកិច្ច លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាខ័ណ្ឌទួលគោក នាយកសាលាបឋមសិក្សាឯកជន អាត់វេនទីសកម្ពុជា និងលោកស្រី **អ៊ុន សម្បត្តិ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាឃាន

៥_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

សេចក្ដីសំរេច លេខ ៥៨៣/សសរ.មស.ក្រខ

ស្ដីពីការបែងចែក និស្សិត ចំនួន ៥០ នាក់ ដែលទើប

បញ្ចប់ការសិក្សាពីបរទេស

***

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ សន.រកត./១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹតលេខ ១៩ អនក្រ [illegible] ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ លេខ ជស រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

សំរេច

ប្រការ១ : អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ៤៩នាក់ ថ្នាក់មធ្យមចំនួន ១នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារនៅក្រសួង ស្ថាប័ន មួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្ដីសំរេចនេះ ។

ប្រការ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និង ផ្តល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ៣ : សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ៥៨៣ សសរ មស.ក្រខ ចុះថ្ងៃទី២២ ខែ ១០ ឆ្នាំ ១៩៩៧
ស្តីពីការបែងចែកនិស្សិតចំនួន ៥០នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

ល.រ	នាមត្រកូល និង នាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំ កំណើត	អង្គភាពដើម	មុខជំនាញ បច្ចេកទេស	កំរិតបណ្តុះបណ្តាល	ប្រភពបណ្តុះបណ្តាល	កំរិតបៀវត្ស	អង្គភាពចូលបំរើការងារ
១	ឡេង ឆាយ	ប	០៥.១០.៧០	សិស្ស	គ្រប់គ្រងពាណិជ្ជកម្ម	ឧត្តម	អាល្លឺម៉ង់	៩០%ខ I ១	ក្រ. ពាណិជ្ជកម្ម
២	អ៊ុក នីវ៉ង	ប	០៥.១២.៦៩	សិស្ស	ភាសារុស្សី និងអង់គ្លេស	ឧត្តមគរុ	សូវៀត	៩០%ខ I ១	ក្រ.អប់រំយុវជននិងកីឡា
៣	សូ ប៊ុនឡេង	ប	០១.០២.៧៣	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៤	ជូ ចន្ទតារាឫទ្ធិ	ប	១៧.១០.៧១	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៥	ថា រិទ្ធ	ប	១៥.០៧.៧០	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៦	តុប ម៉េងហួន	ប	១៥.០៥.៧០	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៧	ឡេង យុត	ប	១៦.០១.៧០	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៨	ឡៅ តារ៉ាវ៉ាត់	ប	១២.០៤.៧២	សិស្ស	ទំនាក់ទំនងអន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
៩	សៅ ខូវ៉ាឌីន	ប	២៦.១០.៦៩	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ទីស្តីការគណៈរដ្ឋមន្ត្រី
១០	អ៊ុន សុវណ្ណសាម	ប	០៨.២.៧៣	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
១១	ជឹង ជោមមុនិន្ទ	ប	០៩.០៤.៧៤	សិស្ស	ទំនាក់ទំនងអន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
១២	វណ្ណ ចាន់តារ៉ា	ប	២៨.០២.៧៣	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
១៣	សោម វិសាល	ប	៣០.១២.៧១	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.យុត្តិធម៌
១៤	អ៊ុន វ៉ានវិបុល	ប	១៨.១១.៦៩	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៥	ផៃ កេតនៈ	ប	០៧.៩.៦៧	សិស្ស	ហិរញ្ញវត្ថុ និងឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
១៦	ពេជ្រ ឃុនបញ្ញា	ប	០៩.៩.៧៣	សិស្ស	សេដ្ឋកិច្ចអន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	

១៧	ពេជ្រ ហ៊ុល	ប	០១.០២.៧០	សិស្ស	ហិរញ្ញវត្ថុ និង ឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៨	ស៊ិន បូណា	ប	០៥.៥.៧៣	សិស្ស	ហិរញ្ញវត្ថុ និង ឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
១៩	សំ ទុយ ហៅសណាត	ប	០៣.៣.៧០	សិស្ស	ហិរញ្ញវត្ថុ និង ឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២០	ខែក ចន្ទី	ប	១៥.១១.៦៩	សិស្ស	វេជ្ជសាស្ត្រទូទៅ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. សុខាភិបាល
២១	យឿប ប៊ុនិន	ប	០៥.០២.៧១	សិស្ស	សេដ្ឋកិច្ច និងការគ្រប់គ្រង	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. ទេសចរណ៍
២២	ឆាយ បូរ៉ា	ប	១៩.៩.៧៣	សិស្ស	បច្ចេកទេសចំរាញ់ប្រេងកាត	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ឧស្សាហកម្មរ៉ែ និង ថាមពល
២៣	ហួត ខន	ប	០១.០២.៧២	សិស្ស	សំណង់ស៊ីវិល និងឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
២៤	ខូយ សុខា	ប	១៥.១២.៧៣	សិស្ស	សំណង់ស៊ីវិល និងឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
២៥	ឈឹម ឈានី	ប	០៥.១០.៧២	សិស្ស	សំណង់ស៊ីវិល និងឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
២៦	ឈឹម បូរ៉ា	ប	១០.៥.៧៣	ប.កសិកម្ម	បច្ចេកទេសគីមីសរីរាង្គ	ឧត្តម	សូវៀត	ខ I ១	ក្រ.កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២៧	ជឹង ដោមមុនី	ប	២៧.៣.៦៦	បុវប្បធម៌	ស្ថាបត្យកម្ម	ឧត្តម	សូវៀត	ខ I ១	ក្រ.វប្បធម៌ និងវិចិត្រសិល្បៈ
២៨	ប៉ែន សុវណ្ណសុខពុទ្ធី	ប	០៣.៩.៧៣	សិស្ស	វិទ្យុទាក់ទង	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ប្រៃសណីយ៍និងទូរគមនាគមន៍
២៩	សុខ ណារ៉េត	ប	១៨.០១.៧៣	សិស្ស	បណ្ដាញនៃប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធគមនាគមន៍	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ប្រៃសណីយ៍ និង ទូរគមនាគមន៍
៣០	សួន សាម៉ុនី	ប	០៦.៣.៧១	សិស្ស	គ្រឿងយន្តនិងការគ្រប់គ្រង	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
៣១	កិន ឆវីរ៉ាន់	ប	២២.០១.៧១	សិស្ស	រ៉ែ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. បរិស្ថាន
៣២	ទេព ទីត្ថ	ប	២៨.៥.៧៣	សិស្ស	ទូរគមនាគមន៍និងប្រៃសណីយ៍	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. ប្រៃសណីយ៍ និងទូរគមនាគមន៍
៣៣	ជិន សុវឌ្ឍនា	ប	១៦.៧.៧២	សិស្ស	អ្នកកាសែត	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
៣៤	ព្រំ កំពូល	ប	១៧.៥.៦៩	សិស្ស	សំណង់ស៊ីវិល និងឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
៣៥	ញ៉ែម សុខុ	ប	០១.០១.៧០	សិស្ស	សំណង់ស៊ីវិល និងឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. មហាផ្ទៃ
៣៦	ប៊ុត សេនា	ប	០២.០៦.៦៩	សិស្ស	ជំនួយការគ្រូពេទ្យ	មធ្យម	សូវៀត	៩០%ខ I ១	ក្រ. សុខាភិបាល
៣៧	ពៅ សោមាណាក់	ប	២៨.៩.៧២	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. កសិកម្មរុក្ខាប្រមាញ់ និង នេសាទ
៣៨	រ៉េង រដ្ឋ	ប	០២.៤.៧១	សិស្ស	បច្ចេកទេសផលិតកម្មរោងពុម្ព	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. អប់រំ យុវជន និង កីឡា

៣៩	ជា តារា	ប	១០.៣.៧៤	សិស្ស	ហិរញ្ញវត្ថុ និង ឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤០	សួន លេន	ប	០៧.៦.៧២	សិស្ស	ហិរញ្ញវត្ថុ និង ឥណទាន	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤១	តាន់ យូហៃ	ប	១៥.១២.៧០	សិស្ស	សេដ្ឋកិច្ច និងផែនការសង្គម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. ផែនការ
៤២	គិន សុជាតិ	ប	០១.៤.៧៦	សិស្ស	កុំព្យូទ័រ	ឧត្តម	សូវៀត	៩០%ខ I ១	រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
៤៣	នួន មនោរម្យ	ប	២០.០១.៧២	សិស្ស	បច្ចេកទេសគីមីឧស្សាហកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ឧស្សាហកម្មរ៉ែ និង ថាមពល
៤៤	កុល ភារិទ្ធ	ប	០១.៥.៧៣	សិស្ស	បើកបរនាវា	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.សាធារណការណ៍និងដឹកជញ្ជូន
៤៥	ស្រាក់ ងួនហុង	ប	០៥.៤.៧២	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ.ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
៤៦	ឈាង ដានី	ប	០៨.១១.៧២	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. កសិកម្មរុក្ខាប្រមាញ់ និងនេសាទ
៤៧	លៀង សេង	ប	០៥.៥.៧៤	សិស្ស	រុក្ខកម្ម	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. កសិកម្មរុក្ខាប្រមាញ់ និងនេសាទ
៤៨	ស៊ិន មុនីវណ្ណ	ប	០៥.៨.៦៥	សិស្ស	បើកបរនាវា	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. សាធារណការណ៍និងដឹកជញ្ជូន
៤៩	សាបូ អូហ្សាណូ	ប	១១.៤.៧៣	សិស្ស	វេជ្ជសាស្ត្រទូទៅ	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. សុខាភិបាល
៥០	ឈ ប៊ុនឆេង	ប	១៥.៥.៧០	សិស្ស	សំណង់ទីក្រុង	ឧត្តម	សូវៀត	៩០%ខ I ១	ក្រ. មហាផ្ទៃ

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួន ហាសិប « ៥០ » នាក់ ប៉ុណ្ណោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ១០ ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

៦_ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៩

សេចក្តីសំរេច លេខ ២១១/៩៧/កធស.

ស្តីពីការរំលាយ « ពុទ្ធិកសមាគមន៍អភិវឌ្ឍន៍កម្ពុជា »

= = =

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មកានិងសាសនា
– បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
– យោងតាមសេចក្តីសំរេចរបស់ក្រសួងធម្មការនិងសាសនា លេខ២១/៩៧ កធស.នធ. ចុះថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ អនុញ្ញាតជាបណ្តោះអាសន្នអោយបង្កើតពុទ្ធិកសមាគមន៍អភិវឌ្ឍន៍កម្ពុជា
– ផ្អែកតបតាមបាតុភាពផ្សេងៗ និងការបែកបាក់សាមគ្គីផ្ទៃក្នុង ក្នុងជួរគណៈកម្មាធិការពុទ្ធិកៈសមាគមន៍អភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ ១៩៩៧ និងពាក្យបណ្តឹងរបស់បុព្វជិត ចុះថ្ងៃទី ២៥_០៨_៩៧ ។

សំរេច

ប្រការ១ : ប្រកាសរំលាយ «ពុទ្ធិកៈសមាគមន៍អភិវឌ្ឍន៍កម្ពុជា »ចាប់ពីពេលនេះតទៅដោយមានមូលហេតុ :

ក/_ មានលេចចេញជាបាតុភាពផ្សេងៗពីគ្រប់មជ្ឈដ្ឋាន នាំអោយប៉ះពាល់ដល់កិត្យានុភាពរបស់ពុទ្ធសាសនា និងប៉ះពាល់ដល់តួនាទីភារកិច្ចរបស់ក្រសួងធម្មការ និងសាសនា

ខ_ មានទំនាស់បែកបាក់សាមគ្គីផ្ទៃក្នុង និងការប្តឹងផ្តល់គ្នាក្នុងជួរគណៈកម្មាធិការនៃសមាគម

គ_ មិនគោរពតាមលក្ខន្តិកៈរបស់សមាគមអោយបានម៉ឺងម៉ាត់

ប្រការ២ : ខុទ្ទកាល័យ នាយកដ្ឋានធម្មការ មន្ទីរធម្មការ និងសាសនាក្រុងភ្នំពេញ គណៈកម្មាធិការពុទ្ធិកៈសមាគមអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នទាំងអស់ដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តនូវសេចក្តីសំរេចនេះអោយបានល្អប្រសើរ ។

ប្រការ៣ : សេចក្តីសំរេចនេះមានប្រសិទ្ធភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា
ហត្ថលេខានិងត្រា
ហៀង វណ្ណារ័ត្ន

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល